## ភាគទី ៩

# ពួកគុរុចូលជាន់ដែនខរាជ

ក្នុងរវាងឆ្នាំទីបំផុតនៃការនិរទេសបាណ្ឌពក្សត្រិយ៍ ទុរយោធន៍បានព្យាយាមស៊ើបសួររកដំណឹងឲ្យដឹងទីសំណាក់ លាក់ខ្លួនពួនអាត្មារបស់ពួកបាណ្ឌពក្សត្រិយ៍ជានិច្ចកាល ។ ចំណែកឯបាណ្ឌពក្សត្រិយ៍ ក៏ខំពឹងពួនលាក់ខ្លួនយ៉ាងស្ងាត់សុខុម ឥតឲ្យអ្នកណាម្នាក់ដឹងដំណឹង ឬលេចឮរបាក់របៀងសោះឡើយ ដូចរឿងមានប្រាកដមកហើយខាងដើម ។ គ្រប់ ៗ ពួកកងក្រវែលដែល ទុរយោធន៍ ប្រើឲ្យទៅស៊ើបសួររកដំណឹងនោះ បានត្រឡប់វិលមកនគរវិញគ្រប់ ៗ គ្នា ដោយប្រាសចាកផលដែលប៉ុនប៉ងទុកមកហើយ ចូលទៅថ្លែងការណ៍ប្រាប់ថ្វាយទុរយោធន៍ថា «ពួកគេបានខ្មីឃ្មាតចេញទៅស៊ើបសួរស្រាវជ្រាវរាវរកខ្លួនបាណ្ឌពក្សត្រិយ៍ គ្រប់ទីកន្លែងដែលមនុស្សផងអាស្រ័យនៅ និងក្នុងដែនដងព្រៃរហោស្ថាន មិនបានជួបប្រទះនឹងយុធិស្ឋិរសោះ ឬគ្រាន់តែឮដំណឹងរសិបរសៀប ក៏គ្មានដែរ» ។ ទុរយោធន៍ទ្រង់សំគាល់ថា «សត្វសាហាវក្នុងព្រៃ មុខជាវាខាំស៊ីពួកបាណ្ឌពក្សត្រិយ៍ទាំង ៥ អស់ហើយ ព្រោះពួកអ្នកដែលត្រូវគេនិរ-ទេសឲ្យទៅដើរព្រៃទាំងប៉ុន្មាន ចេញចាកនិវេសនដ្ឋាន មិនដែលរួចពីមាត់ខ្លាខាំស៊ីទេ» ។ ទុរយោធន៍រឹតតែជឿ ហើយទុកចិត្តយ៉ាងខ្លាំង



រាល់វេលាថា «ពួកបាណ្ឌពក្សត្រិយ៍គ្មានខ្លួនទេ» ទាំងនេះព្រោះព្រះហឫទ័យរបស់ទ្រង់ ប្រាថ្នាតែឲ្យគូបដិបក្ខសូន្យផងទៅអំពីផែនដី ទើបស្រមៃស្រួតទុកដាក់ឲ្យទៅជាយ៉ាងនេះ យ៉ាងនោះជាមុន ។ ឯទោណាចារ្យគ្មានចេតនាព្យាបាទប៉ុនប៉ង ស៊ីសាច់ច្របាច់ឈាមគេដូច្នោះទេ ទាំងភីស្មៈដែលមានព្រះកេសាស្កូវស្រោង ក៏ដូចគ្នាដែរ មិនទ្រង់ជឿសោះថា «បាណ្ឌពក្សត្រិយ៍អស់ព្រះជន្មហើយ» ព្រះអង្គមានព្រះជន្មាយុកាល ៨០ ឆ្នាំហើយ កិច្ចការទាំងពួងទ្រង់ត្រិះរិះហេតុផលឲ្យឃើញជាក់ស្តែងសព្វគ្រប់ជាមុនសិន ទើបបានបញ្ចេញវាចាជាខាងក្រោយ, ក្នុងរឿងនេះក៏ទ្រង់បានរំឭកថា «កុំអាលសន្និដ្ឋានដោយរួសរាន់ហួសពេក សូមទ្រង់ទុកព្រះហឫទ័យថា «ពួកបាណ្ឌពក្សត្រិយ៍ដែលមានអាវុធគ្រប់ដៃដូច្នោះ ក៏ឈ្មោះថាមានពួកច្រើននៅក្នុងខ្លួនសត្វសាហាវយង់ឃ្នង មិនមែនហ៊ានមកប្រឡងឫទ្ធិ ពាធាយាយីបានងាយ ៗ ទេ ទ្រង់អាចតស៊ូនឹងមនុស្ស ឬសត្វសាហាវរាប់រយពាន់បាន, នាយខ្មាន់ធ្នូយ៉ាងអរជុន ជឿថាមុខជាគ្មានសឹកសត្រូវណាលបប្រទូសរ៉ាយបានឡើយ» ។ ព្រះហឫទ័យភីស្មៈ ទ្រង់ព្រួយតែទុរយោធន៍វិញ ក្រែងសត្រូវលបវាយបាន ដោយមិនដឹងខ្លួន ព្រោះហ៊ានប្រមាថមើលងាយទុកចិត្ត ថាសត្វសាហាវខាំបាណ្ឌពក្សត្រិយ៍ស្លាប់បាត់អស់ទៅហើយ ។ ក្រិបាចារ្យក៏យល់ឃើញត្រូវគ្នានឹងទោណាចារ្យ និងភីស្មៈដែរ, គេមិនបានសម្ងំបិទបាំងទុកតែក្នុងចិត្តទេ

កាលទុរយោធន៍ត្រាស់សួរពីរឿងនេះ ក៏ក្រាបទូលមូលមតិតាមត្រង់ ៗ ចំពោះព្រះភក្ត្រថា៖

«ទូលព្រះបង្គំមានសេចក្ដីកង្វល់អំពល់ចិត្ត គិតដល់រឿងនិរាសភ័យនៃព្រះអង្គពន់ពេក មិនសូវជាទៅនឹកនាដល់បាណ្ឌពក្សត្រិយ៍ដែលជឿថាប្រាសចាកភ័យ មានជីវិតរស់នៅរហូតដល់សព្វថ្ងៃនោះប៉ុន្មានទេ ព្រះករុណា! ព្រោះថាទោះបីអាក្រក់ ឬល្អក៏ជារឿងរ៉ាវរបស់គេទេ, ឥឡូវនេះ ឆ្នាំគម្រប់ ១៣ នៃការនិរទេសជិតនឹងអស់ផុតទៅហើយ គួរតែព្រះអង្គខំព្យាយាមផ្សះផ្សារការបាក់បែកគ្នាជាយូរឆ្នាំហើយនោះ ឲ្យដាច់ស្រេចឆាប់ ៗ ទៅ នឹងបានជាផ្លូវសុខកាយសប្បាយចិត្តជងគ្នា លែងភិតភ័យភ្ញាក់ផ្អើលតទៅទៀត, បើមិនដូច្នោះទេ នឹង ......, ប៉ុន្តែ ទូលព្រះបង្គំខ្លាចព្រះហឫទ័យមិនហ៊ានក្រាបទូលរឿងពិតទេ ក្រែងវាមកផ្ដាច់ជីវិតយកទៅក្នុងថ្ងៃណាមួយនៅពេលក្រោយ»។

នាយកងចារបុរសដែលទុរយោធន៍ ប្រើឲ្យទៅស៊ើបការណ៍នោះ កាលបើដឹងថាខ្លួនប្រកែកនឹងគេមិនរួចហើយ ទើបក្រាបទូលថា «ទូលព្រះបង្គំស៊ើបបានព័ត៌មានយ៉ាងល្អ គួរនាំមកក្រាបទូលឲ្យទ្រង់ជ្រាប «យុធិស្ឋិរអស់ព្រះជន្មហើយជាប្រាកដ នៅមានព័ត៌មានល្អវិសេសជាងនេះទៅទៀត គឺកិច្ចកៈកុមារជាព្រះអនុជថ្លៃនៃព្រះបាទវិរាជក្ស័យជន្មដោយដៃមនុស្សកំណាចប្រហារទៅហើយ ទូលព្រះ



បង្គំត្រេកអរណាស់ ហើយនឹកសង្ឃឹមទុកជាមុនថា «មិនមែនជាយូរដល់ទៅប៉ុន្មានថ្ងៃទេ មុខជាទង់ជ័យនៃពួកកោរពដ៏ថ្កើងឫទ្ធិ នឹងទៅប្រតិស្ឋានលើកំពូលប្រាសាទនៃព្រះបាទវិរាជ រលាស់កន្ទុយយ៉ាងរវិច»។

ទុរយោធន៍ នឹកញញឹមប៉ប្រិមក្នុងកមលហឫទ័យ ដូចជាកូនក្មេងកំពុងតែពេញពាល ទ្រង់ព្រះបញ្ជាឲ្យរៀបកងទ័ពជាយ៉ាងប្រញាប់ឲ្យសព្វគ្រប់ទាំងទាហាន ទាំងគ្រឿងយុទ្ធភ័ណ្ឌដើម្បីនឹងលើកទៅវាយក្រុងវិរាជ ។

តមកពីរបីវេលា កងទ័ពកុរុមានសុសរម័ន អ្នកក្លៀវក្លារឹងឫទ្ធិប្រសិទ្ធិក្រៃជាមេទ័ព បានលើកទ័ពយាត្រាសំដៅទៅក្រុងវិរាជសុទ្ធតែកងទ័ពដែលបានចាត់ចែងយ៉ាងឯកគ្រប់ប្រការ ចាត់ដោយផ្ចិតផ្ចង់ណាស់ តាំងពីផែនទីសម្រាប់ដើរទ័ពចូលទៅវាយ នឹងការពារខ្លួនរហូតដល់ឡៀវអាវរបៀបពលសកលយោធា, ចាត់ការរៀបរយដោយបែប ៗ គ្រប់យ៉ាង ។ តាំងពីគ្រាណាមក កងទ័ពកុរុដែលលើកចេញពីក្រុងទៅ មិនដែលសម្ដែងអាការៈក្លាហានរីករាយ ហើយនឹងប៉ុនប៉ងយកជ័យជម្នះដូចម្ដងនេះទេ ។ រឿងស្លាប់កណ្ដាលសង្គ្រាមនោះ គេមិនបានលើកយកមកទុកជាអារម្មណ៍ក្នុងចិត្តសោះឡើយ គេបញ្ជូនចិត្តទៅឈោងចាប់យកទីយុទ្ធភូមិមកជាអារម្មណ៍ឥតរួញរា, ចេះតែស្រើបស្រាលសាទរហ៊ោកញ្ជ្រៀវអឺងអាប់ស្នើរផ្ដាប់ផែនពសុធា ។

សេចក្ដីក្លាហានយ៉ាងនេះ លោកកាត់តម្លៃថ្លៃជាងសេចក្ដីប្រាថ្នារបស់អ្នកមានចិត្តលោភលន់គិតតែខាងបាន ។ គ្រានោះ ព្រះបាទវិរាជបានទទួលសេចក្ដីថ្លែងការណ៍ថា «សឹកលើកមកជាន់ដែនវិរាជហើយ» ទ្រង់ព្រះបញ្ជាឲ្យប្រមូលក្តុំរេហ៍ពល សេនាទាហាន ដើម្បីនឹងលើកចេញទៅតទល់សឹក និងកំចាត់ឲ្យជ្រះស្រឡះចេញអំពីដែនមុនដែលសឹកលើកចូលមកដល់ក្រុង ។ ទ្រង់ធ្វើដំណើរកងទ័ពទៅទទួលសឹកនៅទីកណ្ដាលវាលដ៏ធំធេង ។ កងទ័ពទាំងពីរខាងបានជួបប្រទះប្រទល់មុខគ្នានៅទីនោះ ឈប់ទ្រឹងបង្អង់ស្ងៀមចាំស្ដាប់អាណត្តិសញ្ញាអំពីមេទ័ពដែលនឹងបង្គាប់បញ្ជាឲ្យចូលធ្វើការតយុទ្ធ ។ កងទ័ពទាំងពីរខាងឈរប្រឈមមុខគ្នា ហាក់ដូចជាអ្នកបញ្ជាកងទ័ពទាំងពីរខាងកំពុងតែរៀបចំគ្រឿងថតដើម្បីថតរូបកងទ័ពមុខរបស់ខ្លួនដូច្នោះ មួយស្របក់ សុសរម៉ន អ្នកមេបញ្ជាការកងទ័ពកុរុ ស្រែកប្រកាសថា «ច្បាំង» រន្ទះសូរសៀងលេចឮច្បាស់ទៅដល់កងទ័ពម្ខាង ។

ក្សិណនោះ កូនសរដូចគ្រាប់ភ្លៀង ស្ទុះលឿនឮវ៉ឺ ៗ លើនភាកាសចាក់បញ្ច្រោះបញ្ច្រាសគ្នា ទៅត្រង់ទិសទីទាំងពីរខាងប៉ះទង្គិចគ្នាឮសូរឆាត់ ៗ ឆាប់ ៗ នាកណ្ដាលវេហាស៍ កូនសរខ្លះទៅត្រូវរាងកាយទាហានខាងសឹក, កូនសរខ្លះធ្លាក់ដល់ដី ឥតត្រូវខ្លួនបច្ចាមិត្រសោះ ។ ទាំងពីរពួកចេះតែសង្កួញចោមជិតប្រកិតប្រកៀកចូលទៅកលបីដូចជារលកសមុទ្របុករុកលោលោត ទៅប្រហារគ្នានឹងគ្នា



សមរភូមិ ធ្វើពន្ធនាការនាំយកទៅទុកក្នុងកងទ័ពកុរុ ។ ពួកសេនាទាហានកុរុសប្បាយចិត្តឥតអ្វីនឹងប្រៀបផ្ទឹម ស្រែកហ៊ោថា «ជយោ» ឮសូរកងរំពងស្ទើរផ្អៀងផែនប្រឹថពី ។ កាលគេចាប់បានព្រះបាទវិរាជទៅហើយ ឈ្មោះថាចប់ចម្បាំងមួយភ្លើងប៉ុណ្ណោះ ។

ការដែលគេមើលទៅឃើញម្ចាស់ជីវិតរបស់ខ្លួន ដ៏ជាកំពូលទ័ពមកជាប់អន្ទាក់នៅក្នុងកណ្ដាប់ដៃសឹកនោះឯង ជាអាណត្តិសញ្ញាមកដាស់តឿនចិត្តអ្នកបង្គាប់ការគ្រប់ជាន់ ឲ្យក្រើនសេនាទាហានដែលកំពុងតក់ស្លុត ឲ្យត្រឡប់ជាមានមានះ ខំព្យាយាមរៀងខ្លួនលើសជាងមុន ដើម្បីនឹងច្បាំងដណ្ដើមយកជ័យជម្នះឲ្យទាល់តែបានមកវិញ ។ ពួកទាហានវិរាជប្រឹងប្រែងច្បាំងរុករានដោយមានះដ៏ក្លាហាន ឥតគិតស្ដាយជីវិតសោះ ដើម្បីនឹងជួយម្ចាស់របស់គេ ឲ្យរបូតអំពីអន្ទាក់នៃអរិរាជសត្រូវខ្ជួលខ្ជាញ់សស្រាញ់ចូលទៅ មួយគ្រាហើយ មួយគ្រាទៀត ក៏ទៅតែមិនបានសម្រេចផលដូចប្រាថ្នា ព្រោះកម្លាំងខាងសឹកកំពុងតែក្លៀវក្លាហានខ្លាំងណាស់ ។ ការដែលបែកបាក់ទ័ពថយក្រោយរាល់ដង មុខគួរឲ្យរេហ៍ពលក្រៀករអាចិត្តពន់ពេក ប៉ុន្តែមិនដូច្នោះ ត្រឡប់ជាធ្វើឲ្យទាហានអស់នោះ កើតអស្មិមានះរឹតតែខ្លាំងទ្វេឡើងវិញ ចូលលុកវាយប្រហារមួយហ៊ឹហើយមួយហ៊ឹទៀត ហាក់ដូចជារលកសមុទ្រក្នុងគ្រាត្រូវព្យុះបោកបក់ ការច្បាំងក្នុងលើកនេះឃើញថា ស្រុះគ្នាណាស់ហើយរឹតតែញឹកឡើង ៗ ។ គេមិនបានរួបរួម

ដោយកូនសរ កាន់តែក្រាស់ឡើង ៗ តាមលំដាប់ ឮសូរស័ព្ទអ៊ឹកធឹក តឹកកងកាន់តែខ្លាំងឡើង ៗ ស្ទើរកក្រើករំពើកទាំងផែនពសុធា ។ ចុងក្រោយមក, យោធាទាំងពីរខាងចូលប្រឡុកតស៊ូគ្នាដោយដាវលំពែងអាវុធខ្លីសម្រាប់ដៃ ។

មេទ័ពទាំងពីរខាង មិនគ្រាន់តែដេញបរពលក្នុងបង្គាប់បញ្ជារបស់ខ្លួនឲ្យចូលប្រឡុកគ្នាប៉ុណ្ណោះទេ ថែមទាំងខ្លួនឯងពីរប៉ែកបានចូលប្រយុទ្ធគ្នាផង ដូចជាពលទាហានដែរ ។ កូនសរមេទ័ពខាងកុរុបាញ់មកត្រូវព្រះកាយព្រះរាជាវិរាជមានរបួសបន្តិច សូម្បីត្រូវព្រះកាយដល់មានរបួសម្ល៉េះក្តី ទ្រង់ក៏នៅតែសម្តែងសេចក្តីក្លាហានច្បាំងជាប់រហូតទៅដើម្បីនាំឲ្យស្រើបចិត្តពលរេហ៍របស់ព្រះអង្គ ឲ្យខំច្បាំងតទៅទៀត ។ សូម្បីទ្រង់យកព្រះហឫទ័យទុកដាក់ដល់ម្ល៉ោះក្តី ក្នុងជាន់ដំបូងនេះ នឹងផ្ទឹមមុខទាហានខាងកុរុមិនបាន ព្រោះកងទ័ពខាងវិរាជមិនហាត់ ឬថាមិនសូវប៉ិនប្រសប់ខាងការយុទ្ធវិធីក៏បាន ។ សេចក្តីនេះ ចង្អុលឲ្យឃើញផលក្នុងខណៈនោះ គឺទាហានខាងក្រុងវិរាជចេះតែថយក្រោយ នឹងរុករុលទៅមុខទើសទើរទៅមិនរួច ថយទៅតាំងមាំមួនហើយ ក៏របេះ ៗ ថយចេញទៅទៀត មិនយូរប៉ុន្មាន ក៏ថយរត់ទៅតែម្តង ដោយដឹងថាទប់ទល់នឹងកងទ័ពកុរុមិននឹងសោះឡើយ ។

ក្រោយពីនោះមកបន្តិច សុសរម៉ែនចាប់ព្រះរាជាវិរាជបានក្នុង



កម្លាំងព្រួតដៃគ្នាវាយដោយអន្លើ ៗ ដូចពីជាន់មុនទេ គេពង្រីកជួរទាហានវាយរហូតពេញទីយុទ្ធភូមិ ។ ក្នុងទីបំផុតកងទ័ពកុរុមានអាការធុញទ្រាន់រអាចិត្ត ទៅជារទីសរទាសមិនស្មើកម្លាំងគ្នា ។ ការបានជ័យជម្នះមានចិត្តរីករាយសាទរក្នុងជាន់ដំបូងនោះ ត្រឡប់ជាពោយព្យើរអន្តរធានទៅក្នុងជាន់ក្រោយវិញ ។ ឯសឹកខាងក្រុងវិរាជឡើងចុងដៃ កាន់តែមានកម្លាំងហ៊ឹកហ៊ាកគ្របមកលើខ្លួន ។

ក្សិណនោះ ពល្លក: (នេះជាឈ្មោះបន្លំរបស់ភីមកាលក្លែងភេទចូលទៅនៅក្នុងក្រុងវិរាជ) បានកាន់ក្របីដ៏មានឫទ្ធិ ទៅកាត់ចំណងដែលគេចងព្រះបាទវិរាជ ឲ្យដាច់របូតរួចមកបាន ។ ពួកសេនាទាហានរបស់ព្រះអង្គ នាំគ្នាស្រែកហ៊ោគឹកកងរំពង ទូទាំងទីយុទ្ធភូមិដោយហេតុតែខ្លួនមានជ័យ ។ លើកនេះជាវារៈដែលព្រះបាទវិរាជនឹងធ្វើការសងសឹកវិញ ។ ទាហានវិរាជចូលវាយប្រឡុកកាន់តែស្រុះគ្នា ហើយញឹកដៃឡើងព្រឹម ៗ ចេះតែបានផលល្អតាមលំដាប់ ទាល់តែកងទ័ពកុរុទ្រាំទ្រមិនបាន បែកបាក់ខ្ទាត់ខ្ទាយរត់ចូលក្នុងក្រុងហាស្តិនបុរវិញ ។ គេចាប់សុសរម៉ែន មេទ័ពកុរុបាន ប៉ុន្តែដើម្បីនឹងសម្តែងមេត្តាចិត្ត ព្រះបាទវិរាជត្រាស់ឲ្យលែងខ្លួនសុសរម៉ែន ទៅនគរដើមរបស់គេវិញទៅ ។

កងទ័ពកុរុដែលទុរយោធន៍ បញ្ជូនឲ្យទៅធ្វើសង្គ្រាមនឹងក្រុងវិរាជដោយមនោមានះក្លាហាននោះ ក៏ចប់ផុតត្រឹមគ្រានេះម្តង ។

ឯការសង្គ្រាមដែលទន់ខ្សោយកម្លាំង ចាញ់ប្រៀបគេគ្រានេះ គួរណាស់តែទំលាយចិត្តព្រហើនយង់ឃ្នងរបស់ទុរយោធន៍ ឲ្យធូរថយចុះបានខ្លះ ប៉ុន្តែមិនដូច្នេះ ត្រឡប់ជារឹតតែធ្វើឲ្យទុរយោធន៍កំរើកឫទ្ធិកាន់តែខ្លាំងឡើង ៗ ជាងមុនទៅទៀត ទ្រង់ព្រះបញ្ជាឲ្យប្រមូលភ្ជុំកងទ័ពយ៉ាងប្រញាប់ប្រញាល់ បានល្មមការហើយ ក៏លើកចេញទៅធ្វើសង្គ្រាមនឹងក្រុងវិរាជមួយលើកទៀតជាគ្រាទី ២ ដោយរួសរាន់ ។ គ្រាទី ២ នេះទ្រង់នាំទ័ពដោយព្រះអង្គឯង ។ ទុរយោធន៍លើកកងទ័ពទៅវេលានេះ ជួនជាព្រះបាទវិរាជមានរាជកិច្ច ត្រូវស្ដេចចេញពីព្រះនគរទៅប្រទេសក្រៅ ។ ដំណឹងទ័ពដឹងដល់សេនាបតីរបស់ព្រះអង្គ ។ គេបានប្រជុំគ្នាជំនួសព្រះនេត្រព្រះកាណ៌ ដើម្បីប្រឹក្សារឿងរ៉ាវដែលនឹងចាត់ការតតាំងមហាភ័យកើតឡើងក្នុងបច្ចុប្បន្ន ឲ្យទាន់ពេលអាសន្ននៅសម័យព្រះរាជារបស់គេមិននៅ ។ ព្រះរាជបុត្ររាជ្ជទាយាទ បានទទួលតំណែងជាអ្នកបង្គាប់បញ្ជាកងទ័ពពេញកិត្តិយស ។ គេបានត្រៀមសេះ, ដំរី និងគ្រឿងយុទ្ធោបករណ៍គ្រប់មុខ គ្រប់យ៉ាង ដោយរួសរាន់ ទាំងកេណ្ឌទាហានបញ្ចូលជាថ្មីថែមទៀត បំពេញចំនួនដែលខ្វះខាត ក្នុងកាលធ្វើសង្គ្រាមលើកទីមួយ ឲ្យធួននឹងការដែលបានគិតប្រមាណទុករួចហើយ ។ កើតការរំជើបរំជួលជ្រួលច្របល់ទូទាំងព្រះរាជាណាចក្រ សូម្បីតែស្ត្រីភាពក៏មានភាគជំនួយក្នុងការទ័ព តាមកម្លាំង និងសមត្ថភាពរបស់ខ្លួនដែរ ។ កិច្ចត្រង់នេះ មុខគួរឲ្យកោត



សរសើរចំពោះសេចក្ដីសាមគ្គីនៃអ្នកស្រុកវិរាជណាស់ ។ កាលរៀបចំត្រៀមការទ័ពរួចសព្វគ្រប់ហើយ ក៏បានដំណឹងពីរាជការសឹកមកម្ដងទៀតថា «សឹកលើកចូលមកជាន់ដែនហើយ» ។ កងទាហានអ្នករក្សាការពារក្រុង ក៏ម្នីម្នាលើកចេញទៅរាំងរាទប់ទល់អំពីចម្ងាយ កុំឲ្យសឹកចូលមកដល់ក្រុងទាន់ ។

កងទ័ពទាំងពីរខាង បានពើបពះប្រទះគ្នាមួយគ្រាទៀត ។ ភាពនៃការប្រយុទ្ធបានដំណើរទៅដូចជាលើកទីមួយដែរ គឺថាផ្លាស់ប្ដូរគ្នាឈ្នះចាញ់ជាធម្មតា ។ សេនាទាហានទាំងពីរពួកមានចំនួនច្រើនអនេកអនន្តចូលតយុទ្ធគ្នាខ្នួលខ្នាញ់ឥតស្រាកស្រាន្ត ប្រហែលគ្នានឹងរលកសមុទ្រដេញគ្នាពពួនពពានប្រទះប្រទាក់គ្នាម្ដង ៗ ឮសូរគគ្រឹកគគ្រេង, សម្លេងស្រែកបង្អោ, សម្លេងថ្ងូរទ្រហោយំ, ពាក្យស្បថ, ពាក្យប្រមាថមើលងាយ, ពាក្យផរុសវាទ, ដេរប្រទេចផ្ដាសាទ្រហឹងអឺងកងទាំងដែនយុទ្ធភូមិ ។

នៅពេលកំពុងតែប្រយុទ្ធគ្នានោះ មានកើតរឿងចម្លែកអស្ចារ្យម្យ៉ាងដែលជាតិយោធាអ្នកចម្បាំងទាំងពួងមិនធ្លាប់ប្រព្រឹត្តសោះ ។ រឿងអស្ចារ្យនោះ គឺព្រះរាជបុត្រព្រះបាទវិរាជដែលជាចមពល អ្នកបញ្ជាការកងទ័ពធំខាងក្រុងវិរាជ កាលទ្រង់បានទតឃើញសេនាទាហានចូលកាប់សម្លាប់គ្នាឈាមប្រោលវន្ទាលពេញដាសប្រឹថពី ក៏ទៅជាប្រាបជាន់ឡប់ព្រះស្មារតី ខ្វចព្រះទ័យទប់ពុំបាន ព្រះអង្គលប

ចុះអំពីរថសឹកគេចចេញចាកសមរភូមិ បែរព្រះភក្ត្រសំដៅឆ្ពោះទៅបូរី ។ លុះស្តេចគេចរត់ទៅបាត់ប្រហែលមួយស្របក់ហើយ ទើបនាយសារថីរបស់ទ្រង់ដឹងថា ស្តេចបាត់អំពីព្រះរាជរថទៅហើយ ។ ក្នុងជាន់ដំបូងដែលគេងាកទៅមិនឃើញស្តេច គេនឹកស្មានថា «ព្រះរាជកុមារមុខជាទិវង្គត ដោយស្នាដៃបច្ចាមិត្រទៅហើយ ប៉ុន្តែគេមិនឃើញលោហិតជាប់នៅនឹងព្រះទីនាំងទ្រង់ ដល់មួយដំណក់សោះ នាំឲ្យគេគិតឆ្ងល់ហើយសន្និដ្ឋានថា «ប្រាកដជាស្តេចគេចរត់ទៅបាត់ហើយ» ។ មានសេនាទាហានមួយក្រុម បានទទួលបង្គាប់ឲ្យទៅតាមអញ្ជើញស្តេចត្រឡប់មកកាន់ទីយុទ្ធភូមិវិញ ។ យូរបន្តិចក៏បានឃើញព្រះរាជកុមារអ្នកខ្លាច ត្រូវក្រុមទាហានឃុំខ្លួនដូចអ្នកទោស ឬដូចឈ្លើយសឹកបណ្តើរមកកាន់ទីចម្បាំង ។ ពួកពលរេហ៍របស់ទ្រង់និយាយចាក់ដោតសិកសៀតថា «មិនគួរឡើយនឹងមកសម្តែងសេចក្តីកម្លាចក្នុងវេលាកិត្តិយសដ៏ខ្ពស់មុខ ឬគ្រាទឹកចូលច្រមុះដូច្នេះសោះ» ។ សូម្បីតែនាយសារថីរបស់ទ្រង់ ក៏អត់ទ្រាំមិនបានដែរនិយាយពាក្យគំរោះគំរើយថា «ក្រឡេកឃើញតែឈាមព្រះភក្ត្រស្លេកស្លាំងព្រលឹងស្ទុះចេញបាត់ដូចស្ត្រី» ។ នាយសារថីអ្នកបររថសឹកនៃព្រះរាជកុមារមាននិស្ស័យជាអ្នកចម្បាំង ហើយច្រើនតែជាប់នៅពង្សអ្នកចម្បាំងប្រហែលគ្នានឹងអ្នកអង្គុយលើរថនោះដែរ ។ អ្នកចម្បាំងកំលោះតូច ពោលគឺនាយសារថីនេះ គេអាក់ខានកាន់អាវុធ



នៅដៃជាយូរណាស់ហើយ គេនឹកឃើញថា ការដែលគេនឹងចេញមុខនឹងធ្វើទៅនោះ ជាការសំខាន់ ប៉ុន្តែមកនឹកព្រួយបារម្ភក្រែងព្រះរាជកុមារមេទ័ព នឹងគេចគេបាត់ទៅទៀត សឹកចាប់យកខ្លួនបាន ទើបបររថកាត់សំដៅទៅត្រង់ជ្រុងទីចម្បាំងភាគម្ខាង, លុះគេបររថទៅដល់ដើមឈើដ៏ស្រោងស្រឹង គេក៏ឡើងទៅលើដើមឈើនោះ ហើយយកធ្នូសរនឹងបំពង់ព្រួញដ៏ចាស់ក្រាំគ្រារបស់គេ ដែលលាក់ទុកមកយូរហើយ ក៏ចុះមករកថៅហ្វាយវិញ ឡើងលើរថបរចេញទៅ តាំងចិត្តនឹងជួយតស៊ូអរិរាជសត្រូវរបស់ថៅហ្វាយដោយកូនសរដែលប្រែះចាប់គគ្រើមនោះ ឲ្យទាល់តែឃើញខ្មៅឃើញសនឹងគ្នា ទើបទូលថា «ទូលព្រះបង្គំនឹងបង្ហាញទ្រង់ឲ្យចេះបាញ់ បើទុកជាសេះវានឹងនាំរថទៅឯណាក៏តាមតែវាចុះ ទាហានក្នុងកងទ័ពធំខាងសឹករលស់អស់ជាច្រើនណាស់ហើយ» ទូលយ៉ាងនេះរួច ក៏លើកធ្នូឡើងបាញ់ចេញទៅជាច្រើនព្រួញ ព្រួញមួយទៅធ្លាក់ចំពោះព្រះភក្ត្រភីស្មៈ, ព្រួញមួយទៀតទៅធ្លាក់នៅក្បែរជើងទោណាចារ្យខាងកងទ័ពកុរុ ទោណាចារ្យភ្ញាក់ខ្លួនព្រឺតលាន់មាត់ថា «ច្បាស់ហើយ» កាលឃើញកូនសរបាញ់មកត្រង់ចំពោះដូច្នោះ គេចំណាំកូនសរនេះបាន ទាំងស្គាល់ខ្លួនអ្នកបាញ់ផងទៀត ដឹងថាកូនសរធ្លាក់ក្បែរជើងគេនោះ អ្នកបាញ់មិនបានតម្រង់ឲ្យត្រូវក្បាលគេទេ, អ្នកបាញ់ប្រាថ្នាគ្រាន់តែឲ្យជ្រិះជើងគេប៉ុណ្ណោះ, ហើយងាកទៅរកទុរយោធន៍ ជាស្តេចសឹកក្រាបទូលថា

«ឥឡូវនេះ ទូលបង្គំមានសេចក្ដីព្រួយបារម្ភក្នុងរឿងដែលយើងនឹងដណ្ដើមយកជ័យណាស់ កូនសរនេះមិនមែនជាកូនសរអ្នកដទៃឆ្ងាយទេ ពិតជាកូនសររបស់អរជុន ជាសិស្សអ្នកមានថ្វីដៃរបស់ទូលបង្គំហើយ សិស្សនេះបើទុកជាឈរនៅក្នុងទីប្រទល់មុខគ្នាម្នាងម្នាក់ល្មមបាញ់ទៅត្រូវជាប្រាកដ ក៏គ្មានបំណងនឹងបាញ់ឲ្យត្រូវទូលបង្គំដែរ, តែនេះគេចង់សម្ដែងសេចក្ដីគោរពដល់អាចារ្យចាស់របស់គេបានជាគេបាញ់កូនសរមកឲ្យគ្រាន់តែជិតជើង ជាការតំនាប់ជំនួសខ្លួនគេប៉ុណ្ណោះ» ។ ,

ទុរយោធន៍ធ្វើឫកមាយា ទ្រង់សម្រួលដោយកលឧបាយ ឯក្នុងព្រះទ័យមានសេចក្ដីក្រេកអរលើសលន់ ដែលបានមកជួបនឹងព្រះញាតិអ្នកត្រូវនិរទេសចាកនិវេសនដ្ឋាន តាមសេចក្ដីសន្យាជាយូរហើយនោះ ទ្រង់ក្រេកអរទាំងនេះ ដោយទ្រង់ព្រះតម្រិះថា «ល្អហើយបានជួបគ្នាគ្រានេះ យើងនឹងបានបន្ថែមទោសនិរទេសគេតទៅទៀត ១២ ឆ្នាំ» ទុរយោធន៍ក៏បញ្ចេញសេចក្ដីក្រេកអរក្នុងព្រះទ័យឲ្យភីស្មៈស្ដាប់ ។ ប៉ុន្តែខាងភីស្មៈមិនចង់រវល់ មិនចូលចិត្តរឿងសាងមហាស្ថាន លើនភកល (គំនិតឆ្កួត) ហើយមិនចង់ចូលទៅនៅក្នុងមហាស្ថានជល្មោះ ដែលអ្នកដទៃនិម្មិតឡើង ។

គ្រាដែលភីស្មៈកំពុងតែសន្ទនាជាមួយទុរយោធន៍ នោះរថសឹករបស់ចមពលក្រុងវិរាជ បរតម្រង់ស្ទៅចូលមកដល់ទីនោះ ឮសូរ



សន្ធឹកគគ្រឹកគគ្រេងហាក់ដូចផ្គរលាន់ ថ្លែងសរបាចសាចធ្លាក់ចុះមកត្រង់កណ្ដាលកងទ័ពកុរុដូចជាគ្រាប់ភ្លៀង ។ គ្រាប់ភ្លៀង គឺកូនសរនោះ មិនមែនគ្រាន់តែធ្លាក់ទៅខាងមុខប៉ុណ្ណោះទេបានទាំងធ្លាក់បាចសាចទៅខាងឆ្វេងខាងស្ដាំនៃរថសឹក ដែលបរសំដៅទៅទិសនោះ ៗ ថែមទៀត ។ រថសឹកដ៏ពន្លឹកនោះ ចូលលុកលុយដេញពលខាងបច្ចាមិត្រ ឲ្យបែកខ្ញែកវាលផ្លូងទៅ បរជាន់សេនាទាហានស្លាប់ត្រៀបត្រាកណ្ដាលយុទ្ធភូមិ ។ ក្សិណនោះ នាយសារថីអ្នកមានថ្វៃដៃ ទូលស្ដេចសឹកថា «យើងត្រូវច្បាំងនឹងសឹកយ៉ាងនេះ មើលចុះរេហ៍ពលសកលយោធាខាងបច្ចាមិត្របែកខ្ញែកខ្ចាត់ខ្ចាយទៅហើយ, ខាងយោធារបស់ទ្រង់កំពុងបន្លឺសូរស័ព្ទសាធុការ សរសើរតេជះបារមីរបស់ទ្រង់ថាជាអ្នកមានជោគជ័យ» ។

ព្រះរាជឱរសព្រះបាទវិរាជ ជាចមពលនៃក្រុងវិរាជ ក៏មានជ័យជម្នះឈ្នះសឹកដោយប្រការដូច្នេះ ។ សូរសម្លេងវាស្ត្រនិករ ថ្វាយស័ព្ទសាធុការពរកងរំពងកណ្ដាលពួកសេនាទាហាន ដែលត្រូវរបួសដោយអាវុធមុតជាទម្ងន់ ហើយស្រែកថ្ងូរលល្ងងនោះ ។

ពួកអ្នកស្រុកក៏ហូរហៀរច្រៀតច្បៀតគ្នា មកពាសពេញផ្លូវថ្នល់ដើម្បីសម្ដែងសេចក្ដីអំណរគុណក្នុងរឿងមានជ័យជម្នះ ។ លុះស្រេចការកម្រាបសឹកហើយ អង្គក្សត្រិយ៍សឹកប្រទេសវិរាជ ក៏ទ្រង់ឡើងគង់លើរថសឹកអធិកទៅ ដោយចតុរង្គសេនានិករ ត្រឡប់ថ្កានរាជធានី

វិញ ទ្រង់សន្ទនារីករាយសប្បាយជាមួយនាយសារថី អ្នកភក្ដីរបស់ព្រះអង្គ យាងមកតាមថ្នល់ក្នុងព្រះនគរ ។



## ភាគទី ១០

## ការគប់ប្រុសញ

ថ្ងៃតមកអំពីថ្ងៃដែលមានជ័យនោះ មានកិច្ចប្រជុំធំជាផ្លូវរាជការដើម្បីប្រកាសព័ត៌មាន មុខគួរទទួលបីតិត្រេកអរ ឲ្យប្រាកដកិត្តិយសល្បីល្បាញទូទៅថា «កងទ័ពក្រុងវិរាជមានជ័យជម្នះឈ្នះកងទ័ពកុរុយ៉ាងល្អស្រស់» ។ ព្រះទីនាំងគំនាល់ពេញទៅដោយមនុស្សជ្រៀតបៀតញៀតញាត់គ្នា ស្ទើរតែដកដង្ហើមមិនរួច ។ អ្នកតំណាងរាស្ត្រគ្រប់ពួកគ្រប់ជាន់ បាននាំគ្នាមកកុះករ ដើម្បីសម្ដែងចំណែក នៃសេចក្ដីសោមនស្សរីករាយ ។

នៅមុនពេលដែលព្រះបាទវិរាជ នឹងស្ដេចយាងចេញកាន់ទីប្រជុំនោះ មានរឿងមួយចម្លែកប្លែកអស្ចារ្យ គួរឲ្យនឹកសង្កាណាស់ គឺមានមនុស្សប្លែកមុខម្នាក់ឡើងទៅអង្គុយលើបល្ល័ង្ក សម្រាប់គង់របស់ព្រះបាទវិរាជ ។ មានមនុស្ស ៤ នាក់ទៀតមុខមាត់ក៏ប្លែក ៗ ដែរ តែងខ្លួនដូចយ៉ាងក្សត្រិយ៍ឈរសម្ដែងអាការគោរព ឬគាល់ជុំវិញរាជបល្ល័ង្កនោះ នេះជាឧប្បត្តិហេតុដ៏ស្វាត់កំបាំងធ្វើឲ្យទីប្រជុំមានសេចក្ដីងឿងឆ្ងល់ជាទីបំផុត ប៉ុន្តែគ្មានរាស្ត្រណាម្នាក់ហ៊ានហើបបាមាត់ចរចាជាម្ដេចឡើយ, គ្រាន់តែខ្សឹបខ្សៀវគ្នាតិច ៗ នឹងចេះតែសម្លឹងមើលហើយមើលទៀត ដោយគិតសង្ស័យណាស់ថា «អ្នកប្លែកមុខ

នេះ តើជាអ្នកណាទៅអេះ ? ប៉ុន្តែ មិនមែនអ្នកមានចិត្តក្បត់ចូលមកដណ្តើមយករាជ្យសម្បត្តិទេ ។ អ្នកខ្លះនឹកឃើញស្រពេចស្រពិលមើលទៅប្រហាក់ប្រហែល ដូចជាចាំមុខមាត់អ្នកប្លែកមុខទាំងនេះបានពីរបីនាក់ដែរ តែរកនឹកមិនឃើញថាជាឈ្មោះអ្វីឡើយ។ ចំណែកអ្នកដែលមិនធ្លាប់ឃើញព្រះភក្ត្រព្រះបាទវិរាជ គ្មានគិតសង្ស័យអ្វីសោះ» ។

ក្នុងខណៈដែលអ្នកមើលទាំងឡាយ កំពុងតែនឹកស្មានដោយគំនិតផ្សេង ១ ពីគ្នា ស្រាប់តែព្រះបាទវិរាជ ស្តេចយាងចូលមកក្នុងព្រះទីនាំងគំនាល់ ព្រះភក្ត្រឡើងក្រហមមួយរំពេច នៅវេលាដែលទ្រង់ទតទៅឃើញអ្នកប្លែកមុខ មានចិត្តក្លាហានហ៊ានឡើងទៅអង្គុយលើព្រះរាជបល្ល័ង្ករបស់ព្រះអង្គ ទ្រង់សំគាល់ក្នុងព្រះហឫទ័យថា «ខ្ញុំរាជការក្នុងព្រះរាជវាំងព្រមព្រៀងគ្នាចាត់តាំងឧប្បត្តិហេតុឡើង ជាកិច្ចសម្ភោធន៍នូវការមានជ័យជម្នះលើពួកកុរុ, ព្រះលោហិតពុះខ្ជួលជ្រួលច្របល់ក្នុងព្រះឱរា ព្រោះទ្រង់នឹកដល់សេចក្តីមុខក្រាស់ឥតអៀនខ្មាសរបស់រាជបរិពារទាំងពួងថា«គួរដែរឬ? វានាំគ្នាមកបណ្តែតបណ្តោយឲ្យអាមនុស្សកញ្ជះគេឡើងទៅអង្គុយលើរាជបល្ល័ង្ក លែងសប្បាយតាមអំពើចិត្តវា ជាការទុរាចារដល់ព្រះទីនាំង ដ៏ស័ក្តិសិទ្ធិរបស់ខត្តិយរាជជាទីបំផុតយ៉ាងនេះ» ទ្រង់ជញ្ជីងរំពឹងមើលក្នុងព្រះចិន្តាតទៅទៀតថា «សេចក្តីបញ្ឆើចបញ្ឆើលេងយ៉ាងនេះ ប្លែកពេក



ណាស់ វាគង់តែនឹងកាត់ក្បាលអញចោលថ្ងៃណាមួយមិនខានទេ» ។

លុះស្តេចយាងចូលមកជិត ទ្រង់ចាំមុខអ្នកអង្គុយលើបល្ល័ង្កនោះបានយ៉ាងច្បាស់លាស់ថា អ្នកនោះជាមនុស្សបម្រើរបស់ព្រះអង្គ គឺអ្នកកំសត់ទុគ៌តដែលព្រះអង្គបានព្រមទទួលគេទុកឲ្យនៅជាខ្ញុំល្អងធូលីព្រះបាទដោយព្រះហឫទ័យអាសូរករុណាដល់គេនេះឯង។ កាលបើព្រះបាទវិរាជបានទ្រង់ជ្រាបដូច្នេះហើយ ក៏កើតព្រះទោសោឆេះឆួលរឹតតែខ្លាំងឡើងលើសមុនទៅទៀត ត្រាស់ព្រះសូរសៀងឮក្រេវ ១ ថា «យ៉ាងម្តេចនេះវ៉ុយ »។

តន្តរបាល សេនាបតីម្នាក់ក្រោកឈរឡើងក្រាបទូលថា «សូមទ្រង់បន្ធោបង់ព្រះទោសោទៅសិនចុះ ព្រះករុណា! អ្នកប្លែកមុខដែលអង្គុយលើបល្ល័ង្ករបស់ព្រះអង្គនោះ មិនមែនជាអ្នកដទៃឆ្ងាយទេ ប្រាកដជាមហារាជយុធិស្ធិរ, គួរតែសរសើរថា យើងជាអ្នកមានភ័ព្វវាសនាយ៉ាងវិសេសណាស់ដែលបានព្រះរាជាដ៏ជាប្រមុខនៃក្សត្រិយ៍ទាំងឡាយ មកគង់ជាប្រធានក្នុងទីនេះ»។

ព្រះបាទវិរាជទ្រឹង ត្រាស់មិនចេញមួយស្របក់, ព្រះជីពចរដើរខ្លាំងហើយញាប់ញ័រតឹក ១ ចេះតែទ្រង់នឹកឆ្ងល់ខ្វល់ក្នុងព្រះហឫទ័យ, ព្រះហឫទ័យស្ទុះស្ទះខ្វាត់ខ្វែងមួយរយមួយពាន់សា និងយកជាការអ្វីមិនបានសោះ, លុះទ្រង់ជញ្ជីងរំពឹងមើលសព្វ ១ ទៅ ប្រហែលជាមួយស្របក់ធំ សេចក្តីសន្និះសង្កានោះក៏រលត់រលាយបាត់ទៅ ទើប

ទ្រង់ថ្វាយគំនាប់ព្រះមហារាជយុធិស្ធិរ ដោយគោរពហើយទូលថា «សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោសព្រះករុណា ! សូមប្រទានអហោសិកម្មដល់ទូលព្រះបង្គំ ដែលប្រមាទភ្លាំងភ្លាត់ជ្រួសហួសទៅហើយ ! សូមព្រះអង្គទទួលយកទូលព្រះបង្គំទុកជាខ្ញុំតទៅ» ព្រះករុណាត្រាស់ប៉ុណ្ណេះហើយ ក៏ទ្រង់ព្រះកន្សែងអាក់អួល ដោយទ្រង់នឹករឭកឃើញរឿងរ៉ាវ ដែលកន្លងរំលងផុតទៅហើយ នៅវេលាដែលបាណ្ឌពក្សត្រិយ៍ ក្លែងភេទប្លមចូលទៅបម្រើព្រះអង្គដូចជាបាវព្រាវ, ទ្រង់តូចព្រះហឫទ័យខ្លាំងណាស់ ព្រោះទ្រង់នឹកឃើញពីកាលដែលបានប្រើប្រាស់មហារាជដូចជាបាវព្រាវ, ទ្រង់ជ្រាបក្នុងព្រះអង្គថាបានប្រព្រឹត្តកន្លងល្មើសអកុសលកម្មមួយដ៏ធ្ងន់ ជាកម្មគ្មានផ្លូវនឹងអច្ចយោទោសបាន ក្រៅពីការស្លាប់ទៅប៉ុណ្ណោះ ។

យុធិស្ធិរទតឃើញព្រះរាជាតូចព្រះទ័យជាទុក្ខ ដល់អំពើល្មើសដូច្នោះ ក៏ស្ដេចក្រោកឡើងឈរនៅពីមុខបល្ល័ង្ក ឱបអង្គព្រះរាជាត្រាស់ថា «ខ្ញុំនឹងថ្វាយអហោសិកម្ម ដោយសេចក្ដីប្រមាទភ្លាំងភ្លាត់ដែលទ្រង់ឥតបានក្លែងធ្វើសោះដូចម្ដេចកើត ? គួរតែខ្ញុំវិញទេតើដែលត្រូវសូមអភ័យទោស និងត្រេកអរគុណបុណ្យទ្រង់ ដែលមានព្រះទ័យមេត្តាឲ្យខ្ញុំនៅសំណាក់អាស្រ័យផង នឹងទ្រង់ខ្វល់ខ្វាយឧបត្ថម្ភការពារអន្តរាយក្នុងគ្រាមានគ្រោះថ្នាក់នេះ» ។

- មិនមែនដូច្នោះទេ ព្រះករុណា ! បើប្រសិនជាមានហេតុល្អកើតឡើងក្នុងទីនេះសោត ក៏មិនមែនដទៃឆ្ងាយដែរ ច្បាស់ជាកើតឡើងដោយសារថ្វីដៃដ៏សម្ងាត់ ដែលបានអស់លោកព្រះអង្គក្នុងតំណែងជាចៅហ្វាយនាយ នោះឯងបណ្ដាលឲ្យកើតឡើង, ទូលបង្គំសូមប្រគល់កាយថ្វាយជីវិតជាខ្ញុំបម្រើព្រះអង្គ»។

- អើ ! អើ ! ចូររក្សាសំដីស្នើសុំនេះទុកអភិប្រាយទៅក្នុងកាលទីទៃទៀតចុះ, ទ្រង់ជ្រាបឬទេថា ពួកយើងបានវាយកងទ័ពក្បុរុករានទន្ទ្រានចូលមកជាន់ដែនវិរាជក្នុងគ្រាទី ២ ឲ្យបាក់បបរត់ខ្ចាត់ខ្ចាយបាត់ទៅវិញអស់ ក្នុងគ្រាដែលទ្រង់មិនបានគង់នៅ ?

- ទូលបង្គំទើបនឹងបានដឹងនៅពេលនេះឯង ព្រះករុណា ! ព្រះករុណាមិនទុកព្រះហឫទ័យឬអ្វី ? បានជាលាក់បិទបាំងមិនឲ្យទូលបង្គំដឹងខ្លះថា ព្រះអនុជរបស់ព្រះអង្គ និងរាជិនីទ្រៅបទី ឥឡូវនេះទៅសំណាក់អាស្រ័យនៅទិសទីឯណា ?

- គេសំណាក់នៅទីនេះទាំងអស់គ្នា ប៉ុន្តែគេផ្លាស់ប្ដូរនាមខុសៗ គ្នា ដើម្បីបិទបាំងឈ្មោះដើម នេះគឺនកុល មាននាមថា ត្រន្តិក, នេះសហទេពផ្លាស់នាមជាតន្តរបាល ជាអាមាត្យរបស់ទ្រង់, នេះអរជុនជានាយសារថីរបស់ទ្រង់, នេះភីមផ្លាស់នាមថាពល្លកៈ ជាអ្នកសម្លាប់កិច្ចកៈ, ខ្ញុំមានសេចក្ដីតូចចិត្តជាច្រើន ដែលទើបនឹងមកលាន់រាំចាក្នុងវេលានេះ ឯទ្រៅបទីទេវីផ្លាស់នាមជាសៃរិន្ធ្រីជាស្ត្រីអ្នកគាល់បម្រើជិតដិតរបស់ព្រះរានីវិរាជ ដែលកិច្ចកៈវង្វេងវក់ទៅស្រឡាញ់

ទាល់តែស្លាប់ខ្លួន ។

ព្រះបាទវិរាជទ្រង់ព្រះសណ្ដាប់យុធិស្ឋិរ ថ្លែងរឿងរ៉ាវរហូតមកដល់ត្រង់នេះ ក៏មានសេចក្ដីឆ្ងល់នឹងស្ងើចអស្ចារ្យក្នុងព្រះហឫទ័យណាស់ ។ កាលកិរិយានៃកិច្ចកៈជារឿងនាំឲ្យកើតក្ដីសោយសោកក្នុងកាលដ៏កន្លងទៅហើយ ក៏ពិតមែន ប៉ុន្តែវេលានេះមិនបានមកប៉ះពាល់ដល់ព្រះហឫទ័យដូចជារឿង ដែលទ្រង់បញ្ជាឲ្យ ចងដៃចងជើងទ្រៅបទី បោះទៅក្នុងគំនរអគ្គីទេ ។ វេលានេះទ្រង់ឃើញថា មរណភ័យដែលកិច្ចកៈបានទទួលនោះជាទោសទណ្ឌកម្ម ដ៏ស្រាលស្ដើងសម្រាប់កម្មលាមកដែលកិច្ចកៈប្រាថ្នាលើខ្លួនស្ត្រីម្នាក់ ដ៏ស័ក្ដិសិទ្ធិជាងមាតាបង្កើតបរិសុទ្ធជាងទេពធីតាក្នុងស្ថានសួគ៌, ទ្រង់ឃើញទោសរបស់ព្រះអង្គឯង ដែលបានយល់ព្រមឲ្យព្រះមហេសីធ្វើការរំលោភកាច់កិនសម្មានស័ក្ដិព្រះរាជិនីទ្រៅបទី អ្នកបរិសុទ្ធរកមន្ទិលគ្មាន ។ ទោះបីយុធិស្ឋិរល្ងួងលោមព្រះទ័យដូចម្ដេចក្ដី ព្រះបាទវិរាជក៏ទ្រង់មិនបាត់សោយសោកក្ដួលក្ដៅព្រះហឫទ័យដែរ កាលបើនឹករឭកឃើញរឿងប្រមាទភ្លាំងភ្លាត់ ដែលកន្លងផុតហួសទៅហើយ ក៏រឹតតែកើតវិប្បដិសារៈរសាប់រសល់ខ្វល់ខ្វែងចិន្តាពន់ប្រមាណ។យុធិស្ឋិរទើបអញ្ជើញទ្រង់ឲ្យយាងចូលទីសេយ្យាសន៍ ព្រោះការនិទ្រាជាឱសថសម្រាប់រម្ងាប់សេចក្ដីទុក្ខសោកបាន ម្យ៉ាងហើយត្រាស់ថា «យើងឈប់និយាយហើយ បើសំដីរបស់យើងដែលនិយាយចេញ



ទៅចេះតែធ្វើឲ្យអស្សុជលរបស់ទ្រង់ហៀរហូរដូច្នេះ, ម្នាលមហារាជ! រឿងដែលកន្លងហួសទៅហើយ គួរគប្បីដឹងថាវារួចទៅហើយ មិនគួរនឹងអំពល់រវល់ទៅរំពឹងគិតយកមកវិញទៀត នាំឲ្យវាកើតសោកស្រណោះទទេ ៗ ឥតខ្លឹមសារបន្តិចសោះ, លោកអ្នកមានបណ្ដាស័ក្ដិខ្ពង់ខ្ពស់ជាងខ្ញុំជាច្រើនអ្នកណាស់ បានជួបប្រទះនឹងសេចក្ដីលំបាកលំបិនលើសជាងសេចក្ដីលំបាក ដែលកើតមានដល់ខ្លួនខ្ញុំក្នុងគ្រានេះជាយ៉ាងច្រើនភាគ, ទ្រង់មកបង្ហូរអស្សុជលស្រោក់ដូច្នេះ ធ្វើឲ្យចិត្តខ្ញុំខ្លោចផ្សាពន់ប្រមាណជាងពាក្យប្រមាថមើលងាយ ដែលទ្រង់ស្ដីថាឲ្យខ្ញុំនោះទៅទៀត ឬក៏ឈឺចាប់ជាងការងារដ៏ធ្ងន់ណាមួយដែលទ្រង់បង្គាប់ឲ្យខ្ញុំធ្វើ, ទ្រង់ក៏ជាអ្នកប្រាជ្ញ ចុះដល់ទៅកាលណាអេះ ទើបប្រាជ្ញារបស់ទ្រង់នឹងប្រតិបត្តិរក្សាព្រះអង្គទ្រង់បាន ? បើទ្រង់រម្ងាប់ព្រះហឫទ័យក្នុងរឿងនេះ ចំពោះព្រះអង្គទ្រង់មិនបានទេក៏ចូររម្ងាប់ដោយសេចក្ដីយោគយល់ខ្លួនខ្ញុំចុះ» ។

គ្រានោះ ព្រះបាទវិរាជទ្រង់រម្ងាប់ទុក្ខសោក ផ្លាស់ប្រែព្រះហឫទ័យបាន ដោយទ្រង់ព្រះចិន្ដាថា «រឿងទុក្ខទោមនស្សនេះ មិនមែនធ្វើឲ្យក្ដៅក្រហាយតែខ្លួនឯងម្នាក់ទេ ជាហេតុធ្វើឲ្យក្ដៅក្រហាយដល់ព្រះរាជាធិរាជរបស់ព្រះអង្គផង» ទ្រង់យល់យ៉ាងនេះហើយ ក៏ខំប្រឹងព្យាយាមពេញសតិបញ្ញាដើម្បីហាមឃាត់អស្សុធារា ។

តាំងពីយុធិស្ឋិរ ត្រូវគេនិរទេសទៅដើរព្រៃ, ការទារុណកម្មដ៏

អាក្រក់លាមកជាច្រើនយ៉ាងបានកកើតឡើងក្នុងរដ្ឋសីមាឥន្ទ្របថ, អយុត្តិធម៌ និងការគ្រប់គ្រងមិនត្រូវទំនៀមទម្លាប់បានកើតឡើងទូទៅទាំងព្រះរាជាណាចក្រ, ព្រះរាជវាំងឥន្ទ្របថ កាលពីដើមល្អស្រស់ចិញ្ចែងចិញ្ចាចរកអ្វីប្រៀបផ្ទឹមគ្មាន ដល់មកពេលឥឡូវនេះ ប្រែក្លាយទៅជាសំបុកប្រចៀវ និងព្រាបទាំងឡាយវិញ មានទាំងចោរលួចប្លន់បៀតបៀនអ្នកស្រុកឲ្យបានសេចក្ដីក្ដៅក្រហាយជាញឹកញាប់, របៀបការគ្រប់គ្រងប្រទេស បានផ្លាស់ប្ដូរខុសពីរូបដើមជាច្រើន ព្រោះប្រទេសនីមួយ ៗ ដែលនឹងបានចម្រើនរុងរឿង ដែលអាចនឹងពោលសរុបរួមតែក្នុងពាក្យមួយមាត់ថា «អំណាចជាធម៌» នេះជារបៀបអ្នកធ្វើការគ្រប់គ្រងប្រទេស និងអ្នកនៅក្រោមសេចក្ដីគ្រប់គ្រង, ប្រទេសឥន្ទ្របថដែលធ្លាប់តែមានសុខសាន្តត្រាណ និរាសភ័យមកតាំងពីដើម ត្រឡប់ទៅជាចលាចលស្អុះស្អាប់, និកររាស្ត្រទាំងឡាយចង់បានតែយុធិស្ឋិរត្រឡប់ទៅព្រះនគរវិញ នាំគ្នារាប់ខែរាប់ឆ្នាំចាំមើលផ្លូវព្រះប្រិយមហារាជរបស់គេ ដោយសេចក្ដីរំជួលចិត្ត ។

ព័តិមានរឿងបាណ្ឌពក្សត្រិយ៍ ស្ដេចទៅនៅក្នុងរាជសំណាក់វិរាជ បានលេចឮល្បីសាយភាយចេញទៅដល់នានាប្រទេស ។ ពួកក្សត្រិយ៍សាមន្តរាជ ដែលនៅក្នុងសេចក្ដីគ្រប់គ្រងរបស់ក្សត្រិយ៍មហាសាលយុធិស្ឋិរ បាននាំគ្នាម្ដីម្ដាទៅថ្វានក្រុងវិរាជ ដើម្បីសម្ដែងសេចក្ដីគោរព និងភក្ដីដល់បរមក្សត្រិយ៍ដ៏ជាចៅហ្វាយនាយរបស់ខ្លួន ។ អ្នក



ខ្លះត្រូវដើរជើងទៅ មានសេចក្ដីនឿយព្រួយលំបាកព្រោះមាគ៌ាដ៏ឆ្ងាយដើម្បីឃើញព្រះភក្ត្រមហារាជគម្ដងទៀត ។ អ្នកខ្លះនឹកខឹងប្រណែនឫស្យាព្រះបាទវិរាជ ដែលឲ្យយុធិស្ឋិរ សំណាក់អាស្រ័យនៅក្នុងម្លប់សំយាប ។

ប៉ុន្តែយុធិស្ឋិរ វិលត្រឡប់ទៅនគរវិញ ដោយសុវត្ថិភាពមិនបានទេ ព្រោះទ្រង់ជ្រាបថានឹងត្រូវតែច្បាំងគ្រប់ជំហានដែលឈានត្រឡប់ទៅនគរវិញ ទើបទ្រង់ប្រឹក្សានឹងព្រះបាទវិរាជដែលជារដ្ឋសម្ព័ន្ធមិត្រក្នុងរឿងនេះ ដើម្បីកំណត់ផែនការសង្គ្រាម ដែលនឹងលើកទៅវាយយកផែនដីរបស់ព្រះអង្គដែលខូចខាតទៅនោះ ឲ្យបានត្រឡប់មកវិញថា «ទ្រង់តែងបានជ្រាបហេតុការណ៍ ដែលបណ្ដាលឲ្យយើងត្រូវគេនិរទេសនោះសព្វគ្រប់ហើយ, ពង្សាវតារដ៏ល្បីនាមក្នុងជីវិតរបស់ខ្ញុំអាចនឹងសរុបក្នុងពាក្យតែមួយមាត់បានថា «ការភ្នាល់» ប៉ុណ្ណោះឯង ខ្ញុំយកអាណាចក្រ និងឥស្សរភាពទៅដាក់ភ្នាល់នឹងគេចាញ់គេរាល់ក្ដារ មិនថាក្ដារណាទេ តែបង់ចុះហើយក៏បាត់ទៅអំពីដៃក្នុងក្ដារនោះ មិនត្រឹមតែខូចបង់មកុដរបស់ខ្ញុំ ថែមទាំងបង់ខ្លួនធ្លាក់ទៅជាខ្ញុំគេទៀត ព្រមទាំងព្រៅបទីដ៏ជាបណ្ដូលចិត្ត ប៉ុន្តែការដែលខូចបង់នាងទៅនោះ ខ្ញុំមិនសូវជាទោមនស្សស្មើនឹងសេចក្ដីអាម៉ាស់មុខ ត្រង់ដែលទុហាសាសនៈ វាចាប់សម្រាតនាង កណ្ដាលទីប្រជុំជននោះទេ, គ្រានោះ ចិត្តខ្ញុំតក់ស្លុតសង្វេគស្ទើរទ្រាំពុំបាន ប៉ុន្តែ មានព្រះករុណា

ទិគុណព្រះអយ្យកោភីស្មៈ ដែលទ្រង់បានត្រាស់ជាផ្លូវប្រឹក្សាថា ការដែលធ្វើទោសទណ្ឌកម្មដល់យើង សុំឲ្យធ្វើការនិរទេសចេញចាកនិវេសនដ្ឋានរហូតវេលា ១៣ ឆ្នាំជាកំណត់ យើងក៏ព្រមទទួលទណ្ឌកម្មនោះដោយតុណ្ហីភាព ទោះបីទណ្ឌកម្មនោះតឹងតែងដល់ម្ល៉ោះក្តីក៏ឥតថាអ្វីដែរ យើងបានទទួលសោយកម្មលំបាកលំបិន ដល់ខ្នាតអស់កាលកំណត់និរទេសក្នុងរវាងនោះ សឹងតែពេញពោរទៅដោយសេចក្តីទុក្ខព្រួយយ៉ាងងឹតឈ្លប់ ទើបតែនឹងមកបានឃើញពន្លឺរុងរឿង ពោលគឺសេចក្តីមេត្តារបស់ទ្រង់ ដែលទ្រង់រាក់ទាក់ឲ្យនៅជាសុខក្នុងអំណាចអារក្ខា ក្នុងរាជសំណាក់នេះ ឥឡូវនេះ យើងខ្ញុំទទួលនិរទេសទណ្ឌកម្មនេះដោយសុចរិតគ្រប់គ្រាន់តាមកំណត់ហើយបានប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមខសន្យា ដែលចងរឹតខ្ញុំនោះគ្រប់ប្រការវេលានេះខ្ញុំមានសេចក្តីធូរស្រាលក្នុងចិត្ត គិតនឹងត្រឡប់ទៅស្រុកទេសរបស់ខ្ញុំវិញ នឹងទ្រាំដើរទៅឈប់សំចតឯណោះបន្តិច ឯណោះបន្តិច ដូចចករៀងរហូតនិរន្តរកាលទៅឃើញជាមិនខានឡើយ»។

ព្រះរាជាវិរាជតបថា «ទូលបង្គំជឿជាប្រាកដថា នឹងបានព្រះនគរវិញ ដោយមិនបាច់ធ្វើសង្គ្រាមនោះ ច្បាស់ជាមិនបានឡើយ, ក្របីរបស់យើងតែមួយយ៉ាងប៉ុណ្ណោះ អាចនឹងចាត់ការវិវាទឲ្យស្ងប់ស្ងាត់បាន ឬឲ្យដាច់ស្រេចបាន ព្រោះថារបស់អ្វីដែលបង់ខាតទៅដោយអយុត្តិធម៌នោះ កម្រនឹងបានរបស់នោះត្រឡប់មកវិញដោយ



ប្រក្រតីភាពណាស់»។

ក្នុងរឿងនេះ ទ្រៅបទីក៏យល់ឃើញផងដែរ, នាងជាស្ត្រីភាពក៏ពិតមែនហើយ ប៉ុន្តែនាងជាធីតាក្សត្រិយ៍ ជាតិអ្នកចម្បាំង ហើយជាមហេសីក្សត្រិយ៍ថែមទៀត នាងទើបមានសវនីយ៍ថា «ព្យាយាមសម្រួបសម្រួលបងប្អូនដែលទាស់ទែងខ្វែងគំនិតគ្នាគ្រានេះ ស្មើដូចជាយល់សប្តិ ការទុច្ចរិតបង់ពាក្យសត្យ ត្រូវបានទទួលរង្វាន់តែម្យ៉ាងគឺមរណៈ ទុរយោធន៍យកប្រៀបទ្រង់ដូចម្តេចខ្លះ គេឈ្លាសវៃបញ្ឆោតទ្រង់ឲ្យចូលទៅក្នុងអង្គប់ដែកដូចម្តេច គេក្លែងតែងរោហារធ្វើជាលេងល្បែងភ្នាល់ដូចយ៉ាងញាតិមិត្រ តែគេគិតកលយករាជអាណាចក្ររបស់ទ្រង់ទៅ បណ្តេញទ្រង់ឲ្យចុះចេញចាកផ្ទះសម្បែងនិងព្រាត់ប្រាសចាកប្រយូរវង្សរបស់ទ្រង់ដូចម្តេច ព្រះហឫទ័យរបស់ទ្រង់នៅរាក់ណាស់ មិនចាក់ធ្លុះទៅក្នុងឧបាយកលនោះឡើយ បានជាប្រមាទភ្លាំងភ្លាត់ទៅជ្រៅដល់ម្ល៉េះ ទុកឲ្យការសង្គ្រាមយ៉ាងចេញមុខនេះវិនិច្ឆ័យទៅចុះ ទើបនឹងបានដឹងថា «ខាងណាខុសធម៌ខាងណាត្រូវធម៌»។

ព្រះយុធិស្ឋិរឆ្លើយតាមដែលបានគិតទុករួចមកហើយថា «រៀមបងលចិត្តនាងមើលក្នុងរឿងនេះ តើនាងយល់ដូចម្តេច ? រៀមនឹងបញ្ជូនទូតជាប្រញាប់ ឲ្យនាំព័ត៌មានទៅដល់រាជបរិពារ និងព្រះរាជាដ៏ជាប្រធានក្នុងប្រទេសនោះ ៗ បញ្ជូនរាជទូតមួយប៉ែកទៅកាន់រាជ

សំណាក់ស្រីក្រឹស្ណៈព្រះរាជាប្រទេសទ្វារកៈ ឲ្យយកចិត្តឈឺឆ្អាលជួយបងក្នុងការសង្គ្រាមគ្រានេះ អរជុននេះឯងជាទូតរបស់យើម » ។

លុះព្រឹកឡើង ថ្ងៃតអំពីនេះមក អរជុនក៏អញ្ជើញព្រះរាជសាសន៍ទៅកាន់ក្រុងទ្វារកៈជានគររបស់ព្រះក្រឹស្ណៈ ដែលតាំងនៅមាត់ទន្លេខាងលិចមានរយៈផ្លូវដ៏ឆ្ងាយ ក្រុងនោះឥឡូវនេះហៅថា «គូជរាត» ។ អរជុនធ្លាប់ទៅមកកាន់រាជសំណាក់ក្រឹស្ណៈ ពីឆ្នាំមុន ៗ ក្នុងរវាង ១២ ឆ្នាំដែលត្រូវគេនិរទេសនោះ ។ រាជកុមារទាំង ២ អង្គនេះធ្លាប់ជាសម្ព័ន្ធមិត្រស្និទ្ធស្នាលនឹងគ្នាយ៉ាងខ្លាំងទាំងជាប់ជាព្រះញាតិនឹងគ្នាផង ។ ក្នុងឱកាសដែលទៅគ្រានេះ អរជុនបានឃើញក្សត្រិយ៍ ១ អង្គ តែងកាយយ៉ាងរៀបរយ ដើរចូលទៅក្នុងព្រះរាជវាំងទ្វារកៈទើបនឹងចូលទៅមុន អរជុនមិនទាន់បានប៉ុន្មានជំហានទេ មើលទៅភាពក្សត្រិយ៍នោះ ឃើញថាជាអ្នកដើរផ្លូវឆ្ងាយដូចគ្នា ហើយមើលទៅឃើញថាមានការធុរៈដូចគ្នា ។ អ្នកយាមទ្វារអនុញ្ញាតឲ្យចូលទៅដោយស្រួល មើលទៅកិរិយាដូចជាព្រះរាយសបាយ ឬជាព្រះញាតិនឹងព្រះរាជក្រឹស្ណៈ អរជុននឹកឆ្ងល់ថា ជាអ្នកណាអេះ ? ប៉ុន្តែគ្មានវេលានឹងសាកសួរឲ្យអស់សង្ស័យ ក្នុងរឿងឥតប្រយោជន៍នេះ ព្រោះទ្រង់មកដោយការរាជការយ៉ាងរួសរាន់ ព្រះហឫទ័យខ្វល់ទៅតែក្នុងរឿងរាជការ ។ កាលស្តេចចូលទៅដល់ទ្វារវាំង នាយទ្វារបាលក៏អនុញ្ញាតឲ្យចូលទៅដោយស្រួលដូចគ្នា ដោយមិនចាំបាច់ធ្វើតាម



របៀបដូចសព្វដង ប៉ុន្តែវេលានោះបានទ្រង់ជ្រាបថាក្រឹស្ណៈ កំពុងផ្ទំសម្រាកក្នុងវេលាថ្ងៃរសៀល ទ្រង់ក៏ចូលទៅក្នុងបន្ទប់ក្រឡាបន្ទំ តែមិនមែនជាប្រុងចូលទៅដាស់ទេ ចូលទៅនៅរង់ចាំទីនោះតែម្តងដើម្បីកុំឲ្យខាតពេល កាលបើស្តេចតើនឡើងហើយ នឹងបានទូលស្នើភ្លាមតាមការ ។ នៅខណៈដែលអរជុនឈានចូលទៅក្នុងបន្ទប់ក្រឡាបន្ទំព្រះរាជានោះ មានភ្ញៀវម្នាក់ទៀតជ្រៀតជើងចូលទៅផងដែរ ដើរស្រាវជើងស្រូតទៅមុខអរជុនពីរបីជំហាន រាជកុមារអង្គនោះវាយឫកយ៉ាងធំ ចូលទៅឈរខាងដើមព្រះទែនបន្ទំក្បែរព្រះសិរ ។ អរជុនចូលទៅឈរខាងចុងព្រះទែន ។ ការដែលមានមនុស្សចូលមកពព្រូសពប្រាសយ៉ាងនេះ ជាហេតុធ្វើឲ្យព្រះរាជាតើនឡើងភ្លាមកាលទ្រង់បើកព្រះនេត្រទតទៅ ក៏បានឃើញអរជុនដែលឈរនៅខាងចុងព្រះបាទជាមុន ដោយសេចក្តីបីតិព្រឺព្រួច ព្រោះបានជួបព្រះរាជសម្ព័ន្ធមិត្រដ៏ជិតស្និទ្ធ ក៏ត្រាស់សួរយ៉ាងរួសរាន់ថា « អរជុន ! ទ្រង់មកពីអង្កាល់ ? យើងមានសេចក្តីសោមនស្សខ្លាំងណាស់ ដោយបានឃើញមុខប្រិយមិត្រ» ។

អរជុន «ទូលបង្គំ ទើបនឹងមកអម្បាញ់មិញ» ។

«ទូលបង្គំមកមុន» នេះជាសំដីអ្នកម្នាក់និយាយកាត់ឡើងពាក់កណ្តាល ។ ភ្ញៀវដែលមករកម្ខាងនោះ គឺទុរយោធន៍ ។ កាលក្រឹស្ណៈប្រែព្រះភក្ត្រទៅខាងអ្នកនិយាយក្រោយ អរជុនឃើញទុរយោធន៍

ឈរខាងដើមព្រះទែនថ្វាយគំនាប់ ក៏ត្រាស់ថា «យូរណាស់ហើយ ឋ្មំ ! ទើបនឹងមកជួបគ្នាក្នុងថ្ងៃនេះ, សិទ្ធិជោគស្លោកល្អនាំទ្រង់ឲ្យមកដល់ទីនេះ»។

ទុរយោធន៍ចង់បានក្រឹស្នៈជាសម្ព័ន្ធមេត្រីដោយសិទ្ធិភាព ជាអ្នកមកដល់មុន[១] មិនបានប្រាស្រ័យបដិសន្ថារ ឲ្យយឺតយូរការនិយាយតែកំបុតខ្លី ១ ថា «ទូលបង្គំសូមឲ្យតែព្រះអង្គមានភាគជំនួយក្នុងការសង្គ្រាមដែលនឹងកើតមានមកដល់ សូមព្រះអង្គជាបក្ខពួកខាងទូលបង្គំ» ។

អរជុន មិនបានស្រែកសុំសេចក្ដីជំនួយ ដោយប្រកាន់យកប្រៀបមុនក្រោយដូច្នោះទេ អង្គុយនៅតែស្ងៀម ១ ។ ក្រឹស្នៈជញ្ជឹងគិតមួយស្របក់ហើយក៏ត្រាស់ថា «ខ្ញុំឥតទើសទាល់សល់ក្រអ្វីទេ ក្នុងការដែលនឹងប្រគល់កម្លាំងយោធារបស់ខ្ញុំ ឲ្យទៅដើម្បីជាប្រយោជន៍ដល់ទ្រង់អង្គណាមួយ ឬក៏ពីរខាង ប៉ុន្តែខ្ញុំសូមប្រកាសបំភ្លឺផ្លូវត្រង់រឿងនេះបន្តិចសិន តាមសេចក្ដីយល់ឃើញរបស់ខ្ញុំថា អ្នកទាំងពីរមានភាគស្មើគ្នាដើម្បីនឹងរក្សាជញ្ជីងត្រាជូឲ្យទៀងត្រង់ រវាងសេចក្ដីជាសម្ព័ន្ធមិត្រសម្រាប់ខ្លួន និងសម្រាប់ប្រទេស ខ្ញុំសូមប្រគល់កងទ័ពជើងគោក និងកម្លាំងទ្រព្យទាំងពួងក្នុងអាណាចក្រឲ្យទៅអ្នកម្ខាង ឯ

១) ព្រោះតាមប្រពៃណីក្សត្រិយ៍ឥណ្ឌាបុរាណប្រកាន់ថា បើកើតហេតុទាស់ទែងគ្នាឡើង នឹងសុំឲ្យជួយរវាងបដិបក្ខ គេច្រើនតែទទូលជួយខាងអ្នកមកដល់មុន ។



អ្នកម្ខាងទៀត ខ្ញុំចង់ប្រគល់ខ្លួនខ្ញុំឲ្យតែម្ដង ដោយឥតកាន់អាវុធ ឬស្បៀតក្រសពាក់ក្រោះ គ្រឿងការពារខ្លួនឡើយ ឥឡូវនេះ សូមឲ្យទ្រង់ទាំងពីរខាងរើសយកតាមគាប់ចិត្តរៀងខ្លួនចុះ» ។

ទុរយោធន៍ទូលដោយរួសរាន់ថា «ទូលបង្គំសុំទទួលយកខាងកងទ័ពជើងគោក និងទ្រព្យធនទាំងពួង ឲ្យជារបស់ខាងទូលបង្គំ» ។

អរជុនទូលថា «ទូលបង្គំមានសេចក្ដីត្រេកអរយ៉ាងក្រៃលែង ដោយបានក្រឹស្នៈ មកជាពួកខាងទូលបង្គំ, ទូលបង្គំវាយតម្លៃមិត្តភាពដូចយ៉ាងក្រឹស្នៈខ្ពស់ជាងកម្លាំងវរហ៍ពលសកលយោធារបស់ព្រះអង្គ» ។

គ្រានោះ កងទ័ពជើងគោករបស់ព្រះបាទក្រឹស្នៈ ក៏ចាត់ការលើកទៅក្រុងហាស្តិនបុរដោយរួសរាន់ ។ ទុរយោធន៍ជាអ្នកនាំកងទ័ពនេះទៅដោយព្រះអង្គឯង ។ នៅវេលាជាមួយគ្នានោះ ក្រឹស្នៈក៏ស្ដេចតាមអរជុនទៅក្រុងវិរាជដែរ ស្ដេចយាងទៅគ្រានេះ ឥតកាន់អាវុធឥតរាជបុរសតាមហែព្រះអង្គទៅផងទេ ។ កាលក្សត្រិយ៍ទាំងពីរអង្គយាងទៅដល់រាជសំណាក់ព្រះបាទវិរាជហើយ មានការប្រជុំប្រឹក្សាសើរើរឿងបាណ្ឌពក្សត្រិយ៍សាជាថ្មីឡើងវិញ ។ ក្រឹស្នៈគង់ជាប្រធានក្នុងទីប្រជុំនោះ ទ្រង់ព្យាយាមប្រុងតែនឹងបំបាត់មិនឲ្យកើតមានសង្គ្រាមកាប់សម្លាប់គ្នាឡើយ វេលានោះទ្រង់ក្រោកឈរឡើង ចាប់ផ្ដើមថ្លែងសុន្ទរកថាសង្រួបសង្រួមដើម្បីឲ្យស្ងប់សឹក និងដើម្បីជាមិត្ត

ភាពក្នុងទីបំផុត ក្រុមប្រឹក្សាបានព្រមព្រៀងគ្នាតាមពាក្យណែនាំរបស់ក្រឹស្ណៈ ឲ្យបញ្ជូនរាជទូតទៅគាល់ព្រះរាជាធ្ឫតរាស្ត្រ ជាព្រះញាតិធំបំផុតដើម្បីធ្វើការសម្រុះសម្រួល ដោយសាមគ្គីភាពជាមួយនឹងពួកកោរព ។



## ភាគទី ១១

## ប្រឹក្សាការស្ងប់សឹក-ត្រៀមចម្បាំង

រាជទូតរបស់យុធិស្ឋិរបានដល់ក្រុងហាស្តិនបុរហើយ ក៏សំដៅត្រង់ចូលទៅគាល់ក្នុងព្រះទីនាំងតំនាល់ ក្រាបទូលមូលគតិថា ៖

«ព្រះរាជារបស់ទូលព្រះបង្គំជាខ្ញុំ ត្រាស់ប្រើឲ្យទូលបង្គំមកក្រាបទូលព្រះអង្គថា«បាណ្ឌព និងកោរព ជាបងប្អូនជីដូនមួយនឹងគ្នា ហេតុម្តេចក៏ឱរសធ្ឫតរាស្ត្រ បានរាជអាណាចក្រទាំងមូលគ្រប់គ្រង, ឱរសបាណ្ឌុឥតបានអ្វីនឹងគេសោះ សូម្បីគ្រាន់តែធូលីមួយក្តាប់ក៏គ្មានផង ? ទុរយោធន៍គិតព្យាបាទព្រះញាតិវង្សរាល់ទិវារាត្រី ធ្វើឧបាយកលឲ្យទៅអញ្ជើញគេមកលេងស្កាភ្នាល់, ឯអ្នកស្កាដៃសំខាន់របស់ទុរយោធន៍ យកស្កាបង្កប់សំណាមកលេងដោយកលកោងនឹងព្យាបាទ, ឯយុធិស្ឋិរលេងទៅដោយជឿចិត្តថាបងប្អូនក៏ចាញ់រាល់ ៗ ក្តារ ត្រូវបង់ទ្រព្យស្រីង្គារបរិវាររបស់គេទៅឲ្យទុរយោធន៍ រលីងអំពីខ្លួនដូចគជ, ទុរយោធន៍ក៏ចេះតែកើបកោយច្រកទៅឥតញញើតដៃ, ក្នុងទីបំផុតត្រូវនិរទេសខ្លួន ទៅនៅក្នុងដែនដងព្រៃភ្នំក្រំថ្ម បានទទួលប្រតិបត្តិតាមខសន្យាយ៉ាងឧក្រិដ្ឋ ដែលកម្រមានមនុស្សទាំងពួងលើផែនដីនឹងធ្វើបាន, ក៏ឥឡូវនេះ គេបានប្រតិបត្តិតាមខសន្យានោះធួនបរិបូណ៌សព្វគ្រប់ហើយ ថែមទាំងបានបំភ្លេចរឿងហេតុការណ៍ទាំង

ពួងក្នុងអតីតកាលនោះ មិនឲ្យមកកើតកោសូសសន្តានចិត្តទៀតផង, ប្រសិនបើប្រគល់រាជណាចក្ររបស់គេ ឲ្យទៅគេវិញដោយស្រួល ៗ ហើយ ក៏មុខជាមិនកើតការកាប់សម្លាប់គ្នាឡើយ បើពាក្យសុំត្រឹមត្រូវតាមធម៌យ៉ាងនេះហើយ ត្រឡប់ជាជាត់ចោលមិនទទួលសម្រេចឲ្យតាមផ្លូវយុត្តិធម៌វិញទេ ក៏ត្រូវតែប្រកាសសង្គ្រាមនឹងគ្នាពេញវយ:, ជឿទុកជាមុនថាពួកកុរុ គ្រានេះនឹងខ្ទេចខ្ទីទៅជាផេះធូលី, ដែនដីទាំងនោះពួកបាណ្ឌពនឹងរឹបអូសយកទាំងមូល» រាជទូតក្រាបទូលប៉ុណ្ណេះហើយ ក៏នៅស្ងៀមចាំស្តាប់ព្រះរាជតម្រាស់តប ។

ព្រះវាចារបស់យុធិស្ធិរ ដែលប្រើឲ្យរាជទូតទៅនិយាយជំនួសនោះ ស្តាប់ទៅត្រូវព្រះទ័យភីស្មៈច្រើន ប៉ុន្តែបើជាខុសនឹងចិត្តទុរយោធន៍យ៉ាងឆ្ងាយស្រឡះវិញ ។ កាលទុរយោធន៍បានឮរាជទូតទូលដូច្នោះហើយ ព្រះទ័យក៏បណ្តាលខ្នួលខ្នាញ់ឡើង ត្រាស់ព្រះសូរសៀងម៉ឹងថា «អាក្រជាំនោះ វាហ៊ានចូលមកនៅទទឹងមុខរាជសីហ៍ក្នុងគុហាបាន, ចូរប្រាប់វាផងថា ពាក្យគំរាមប៉ុណ្ណេះមិនបានធូនល្មមនឹងធ្វើឲ្យ រយោធន៍ ព្រឺរោមជាជាងស្វាព្រាមដែលវាញេញធ្មេញឲ្យអញនោះទេ, ក្លាមាត់មិនស្មើនឹងក្លាថ្វីដៃទេ ដ្បិតថាក្លាមាត់គ្រាន់តែវលាស់អណ្តាតអួតពូកែផ្ទួងផាង សុទ្ធតែខ្យល់ទទេ ដែលនឹងយកឲ្យបានជាការមែនទែន ដល់ទៅចាប់អាវុធចូលប្រឡូងសឹកតស៊ូថ្វីដៃគ្នាឃើញជាឥតបានការសោះឡើយ ចូរប្រាប់យុធិស្ធិរ និងបក្ខពួករបស់



គេផងថា «ពាក្យគំរាមគ្រាន់តែជាខ្យល់ ៗ ប៉ុណ្ណឹង មិនមែនធ្វើឲ្យទុរយោធន៍ព្រឺព្រួចរោម ដល់ទៅលើករបស់ដែលបានមកនៅក្នុងកណ្តាប់ដៃហើយ ដោយជ័យជម្នះឲ្យទៅវិញទទេ» ចូរប្រាប់បាណ្ឌពក្សត្រិយ៍ ឲ្យបែរមុខទៅកាន់ព្រៃភ្នំម្តងទៀត ហើយសឹមមកថ្វាយដីកាប្រឹក្សាសុំទោសនឹងព្រះរាជាទុរយោធន៍ ស្រេចតែព្រះអង្គនឹងទ្រង់ព្រះមេត្តាប្រោសដូចម្តេច»។

ព្រះបាទធ្រួតរាស្ត្រ ទ្រង់ហាមប្រាមព្រះរាជឱរស ហើយត្រាស់មចុរកថា ទៅនឹងរាជទូតថា «ពាក្យលើសលែងស្លែងស្រោគ្រ ដែលទុរយោធន៍និយាយហួសទៅហើយនោះ ចូរអ្នកកុំប្រកែប្រកាន់យកជាអារម្មណ៍ឡើយ សំដីទុរយោធន៍ច្រើនតែឲ្យទោសជាងដែលឲ្យគុណ, យើងមានរាជសាសន៍ទៅដល់យុធិស្ធិរថា «យើងនឹងបញ្ជូនរាជទូតរបស់យើងទៅជាប្រញាប់ ដើម្បីនឹងចាត់ការសម្រួបសម្រួមទាំងពីរខាងឲ្យព្រមព្រៀងគ្នាដោយស្រួល ៗ »។

តាមសេចក្តីប្តេជ្ញានេះ ធ្រួតរាស្ត្របានបញ្ជូនសេនាបតី និងនាយសារថីឈ្មោះសញ្ជ័យឲ្យទៅគាល់បាណ្ឌពក្សត្រិយ៍ឲ្យទូលថា «បើទ្រង់ប្រាថ្នារកសេចក្តីស្ងប់សឹកឲ្យបានសុខសាន្តត្រាណនិរាសភ័យផងគ្នាសូមអញ្ជើញមករកខ្ញុំចុះ ខ្ញុំនឹងបានប្រកាសកាត់សេចក្តីឲ្យតាមដោយយុត្តិធម៌»។

កាលសញ្ជ័យ នាយសារថីបានដល់ក្រុងវិរាជហើយ ក៏នឹក

ងឿងឆ្ងល់ណាស់ ដោយបានឃើញបាណ្ឌពក្សត្រិយ៍ ប្រជុំរេហ៍ពលសកលយោធាត្រៀបត្រាមុខគួរឲ្យស្ញប់ស្ញែង ។ ទោះបីដូច្នោះក្តី គេក៏មិនបានយកចិត្តទុកដាក់នឹងកងទ័ព ព្រោះគេមិនបានមកក្នុងឋានៈជាចារបុរស គេមកក្នុងឋានៈរាជទូត ហេតុដូច្នោះ បានជាគេមិនរវល់នឹងក្រួតត្រាមើលកងទ័ពបាណ្ឌពក្សត្រិយ៍ គេដើរតម្រង់ចូលទៅក្នុងព្រះរាជវាំងតំនាល់ លុះស្រេចការបដិសណ្ឋារហើយ ក៏ក្រាបទូលថ្វាយរាជសាសន៍ដល់យុធិស្ឋិរ ។

ឯព្រះយុធិស្ឋិរមិនសូវពេញព្រះហឫទ័យ ក្នុងព្រះរាជសាសន៍នោះទេ ព្រោះនិយាយសេចក្តីខ្លីពេក ទើបទ្រង់ត្រាស់ថា «យើងគោរពព្រះបាទធ្មតរាស្ត្រខ្លាំងណាស់ ប៉ុន្តែខ្លាចក្រែងទ្រង់នឹងវង្វេងជឿពាក្យឧបាយកលរបស់ឱរសទៀត, សព្វថ្ងៃនេះ ទុរយោធន៍ចេះតែគិតនឹងគ្រញេចយើងឲ្យខ្ទេចខ្ទីទៅជាធូលីប៉ុណ្ណោះ, ឯមហារាជជាម្ចាស់ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន សេចក្តីរក្សាការពារយើងស្មើមាតាបិតារក្សាបុត្រ ប៉ុន្តែមិនព្រមព្រះរាជទាន តាមពាក្យរបស់យើងស្រែកសុំដ៏ត្រឹមត្រូវតាមច្បាប់ខត្តិយប្រពៃណី» ទ្រង់រំពឹងមួយស្របក់ហើយ ក៏ត្រាស់ទៅនឹងរាជទូតខ្លះទៀតថា «បើទុកជាធ្វើយ៉ាងណា ក៏នៅតែកើតសឹកសង្គ្រាមមិនខានដែរ ឥតផ្លូវណានឹងកែប្រែចៀសវាងឲ្យផុតឡើយ យុត្តិធម៌ក៏ល្មមតស៊ូគ្នានឹងយុត្តិធម៌បានហើយ ប៉ុន្តែបើយុត្តិធម៌ទៅតស៊ូនឹងអយុត្តិធម៌វិញ ត្រូវតែបែរទៅអាស្រ័យ



កម្លាំងកំណាចយកមកតស៊ូទើបកើត ឱអនិច្ចា! មុខគួរឲ្យសង្វេគស្លុតចិត្តពេកណាស់ចំពោះការដែលញាតិវង្ស ត្រូវកាប់សម្លាប់គ្នាស្លាប់ដូចគេបាល ឮតែសូរសម្រែកស្រីមេម៉ាយស្រែកយំទួញ និងសម្លេងក្មេងកំព្រា ឥតផ្ទះសំណាក់អាស្រ័យដោយព្រាត់ប្រាសពីឪពុកម្តាយ, មុខគួរឲ្យស្តាយរបស់ដែលកំពុងតែចម្រើន និងជាទីលំអក្នុងព្រះនគរមកត្រូវវិនាសខ្ទេចខ្ទីទៅក្នុងកាលមួយរំពេចប៉ុណ្ណោះ, បុព្វបុរសរបស់យើង លោកបានខំប្រឹងព្យាយាមកសាង ដោយការនឿយហត់ជាអនេករាប់ចំនួនច្រើនតំណមនុស្សមកហើយ នៅវេលានេះមុខជាសាបសូន្យស្នាដៃរបស់លោកមិនខាន, ឱ! មុខគួរឲ្យស្តាយនូវសេចក្តីសង្ឃឹមរបស់និករាស្ត្រ ដែលគេនឹកសង្ឃឹមលើយើងរាល់ព្រឹកល្ងាចថាយើងនឹងបានត្រឡប់វិលចូលទៅក្នុងព្រះនគរវិញដោយសុវត្ថិភាពរៀបរយ, ឥឡូវនេះគេមុខជាឃើញតែយុទ្ធកម្ម មុខគួរឲ្យស្ញប់ស្ញែងណាស់ ពលរេហ៍ដើរព្រឹប ៗ ឆ្លងដែនចូលទៅ ធ្វើឲ្យកើតសេចក្តីវិនាសហិនហោចដល់អ្នកធ្វើការរំលោភសង្កត់សង្កិនគេ និងគ្រប់គ្រងស្រុកទេសមិនត្រឹមត្រូវតាមផ្លូវយុត្តិធម៌ ឲ្យខ្ចាត់ខ្ចាយបាត់អស់ទៅ, កក្ខឡកម្មទាំងពីរយ៉ាងនេះ បានកើតមានឡើងតាំងពីវេលាដែលយើងនាំគ្នាចេញចាករដ្ឋសីមា ប៉ុន្តែវេលានេះយើងនឹងឲ្យក្រឹស្ណៈជាអ្នកតំណាងទៅក្រុងហស្តិនបុរ ដើម្បីនឹងប្រឹក្សាពីកិច្ចរាជការក្នុងស្រុកទេស ឲ្យបានត្រឡប់រួបរួមមូលជាមួយគ្នាឲ្យជាសុខសាន្តត្រាណ

តទៅ ចំណែកឯយើងនៅខាងណេះ ក៏នឹងខំប្រឹងប្រែងឲ្យដល់ខ្នាតដើម្បីចៀសវាងការសង្គ្រាម, សូមឲ្យសេចក្ដីសម្រេចផលប្រយោជន៍បានកើតមានឡើងក្នុងកណ្ដាប់ដៃនៃលោកជាម្ចាស់ទឹកដី ដែលជាប្រធានក្នុងការសន្តិភាព និងការចម្បាំង»។

សញ្ជ័យថ្វាយបង្គំលាត្រឡប់ទៅដល់ក្រុងហាស្តិនបុរវិញ ទូលគាល់ព្រះបាទធ្ឫតរាស្ត្រ ទូលថ្លែងតាមក្រសែព្រះរាជតម្រាស់របស់ព្រះយុធិស្ឋិរថា៖

«មហារាជដ៏ចម្រើន ការដែលទ្រង់ត្រាស់ប្រើទូលព្រះបង្គំជាខ្ញុំឲ្យទៅឯក្រុងវិរាជនោះ បានសេចក្ដីថា មើលទៅមុខជាមានអន្លង់នៃការបែកសាមគ្គីរវាងកោរព និងបាណ្ឌពក្សត្រិយ៍ ជាប្រាកដ អន្លង់នេះមានសឹងសង់ស្ពានឆ្លង ដោយសេចក្ដីសម្រួបសម្រួមឲ្យស្ងប់សង្គ្រាមឲ្យរហូតទៅដល់ត្រើយមិនបានទេ ម្ដងនេះនឹងផ្សារឡើងវិញឃើញជាលែងជិតហើយ, ចិត្តយុធិស្ឋិរប៉ុនប៉ងចង់បានតែអាណាចក្រពាក់កណ្ដាលសម្រាប់ខ្លួនគេដូចពីដើម ថាបើយើងមិនព្រមបង្វិលឲ្យគេវិញទេ មុខជានឹងកើតសឹកសង្គ្រាម កាប់សម្លាប់គ្នាជារឿងវិនិច្ឆ័យក្នុងរឿងនេះ គ្មានផ្លូវណានឹងចៀសវាងឲ្យផុតពីសង្គ្រាមទេ ទូលព្រះបង្គំជាខ្ញុំបានឃើញសេនាទាហានខ្លាប់ដែលពួកបាណ្ឌពក្សត្រិយ៍ ត្រៀមទុក ព្រោះហេតុនោះ ដែលគេប្រើរាជទូតឲ្យមកគំរាមយើង មិនមែនគ្រាន់តែគំរាមលេង ៗ ទេ ជាពាក្យស្រែកប្រកាសរបស់គេម្យ៉ាង បើ



ខុស ឬត្រូវយ៉ាងណាក៏តាមការចុះ សម្រេចឲ្យដាច់ស្រេចនឹងគ្នា ត្រង់កងទ័ពដ៏មានកម្លាំង ទើបអាចនឹងវិនិច្ឆ័យឲ្យជ្រះស្រឡះទៅបាន ហេតុនេះសេចក្ដីយល់ឃើញយ៉ាងជាន់ទាប ៗ របស់ទូលព្រះបង្គំជាខ្ញុំថា «គួរតែចៀសវាងការសង្គ្រាមឲ្យផុត កុំបីឲ្យកើតរឿងកាប់សម្លាប់គ្នាឡើយ»។

ព្រះបាទធ្ឫតរាស្ត្រត្រាស់ថា «អ្នកនិយាយយ៉ាងនេះត្រូវហើយ យើងក៏មិនចូលចិត្តកាត់សេចក្ដីដោយច្បាប់ព្រៃ យកការកំហែងទល់នឹងកំហាល់ដែរ, យើងនឹងខំប្រឹងប្រែងឲ្យពេញកម្លាំងដើម្បីរក្សាការស្ងប់សឹកឲ្យ បានសុខសាន្តត្រាណក្នុងប្រទេស»។

តាមសេចក្ដីប្ដេជ្ញាដែលព្រះយុធិស្ឋិរ បានធ្វើទុកនឹងសញ្ជ័យអំពីថ្ងៃមុនរួចមកហើយនោះ ទ្រង់ក៏បញ្ជូនក្រឹស្ណៈទៅឯក្រុងហាស្តិនបុរដើម្បីនឹងសម្រួបសម្រួមការវិវាទនៃព្រះញាតិវង្សទាំងពីរខាង កាលដល់ក្រុងហាស្តិនបុរហើយ ព្រះបាទធ្ឫតរាស្ត្របានធ្វើបដិសណ្ឋារពេញកិត្តិយស មានសេចក្ដីគារវនឹងស្នេហាមេត្រី អាស្រ័យគ្នាទៅវិញទៅមកដោយរីករាយ ព្រោះក្រឹស្ណៈក៏មិនមែនគ្រាន់តែជាក្សត្រិយ៍ទ្រង់នូវមហិទ្ធិឫទ្ធិម្យ៉ាងប៉ុណ្ណោះទេ ថែមទាំងជាប់សែស្រឡាយជាព្រះញាតិវង្សមួយអង្គផង ទ្រង់ប្រាស្រ័យនឹងក្រឹស្ណៈថា «ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលទ្រង់បានស្ដេចមកប្ដាន សំណាក់ទូលបង្គំ ហើយទូលបង្គំមានសេចក្ដីត្រេកអរពេញហឫទ័យណាស់ ដើម្បីទទូលស្គាល់

ទ្រង់ជាពិតប្រាកដ ទូលបង្គំមិនដឹងបើយកពាក្យអ្វី មកសម្តែងអំពីបីតិរបស់ទូលបង្គំបានទេ»។

ក្រឹស្ណៈតបថា ៖

«ខ្ញុំមកអំពីក្រុងវិរាដដើម្បីកិច្ចការរបស់បាណ្ឌព»។

ធ្ឫតរាស្ត្រ «ដើម្បីអ្វីក៏តាមការចុះ សូមឲ្យត្រាស់ប្រាប់មក ទ្រង់តែងនាំសេចក្តីបីតិប្រាមោទ្យមកកាន់ក្រុងហស្តិនបុរជានិច្ច ទូលបង្គំមានអំណរនឹងចាំស្តាប់មធុរកថារបស់ទ្រង់ ប៉ុន្តែសញ្ជ័យរាជទូតរបស់ទូលបង្គំ ទើបនឹងត្រឡប់អំពីរាជសំណាក់វិរាដមកវិញ ទូលបង្គំត្រូវតែនិយាយថា មិនសមប្រាថ្នាក្នុងផ្លូវរាជការដែលគេទៅ ព្រោះគេទៅនិយាយបញ្ចុះបញ្ចូលផ្សះផ្សារការបែកបាក់គ្នារវាងសាខានៃព្រះញាតិវង្សម្តងហើយ មិនបានរួបរួមគ្នាដោយស្រួលបួល, ទូលបង្គំនិយាយនេះតាមសេចក្តីរាយការណ៍របស់រាជទូតដែលមកថ្លែងប្រាប់ទូលបង្គំ, កាលបើយុធិស្ឋិរមានចេតនាប៉ុនប៉ងនឹងធ្វើសង្គ្រាម គ្មានខាងណាលស់លាត្រាប្រណីហើយ ក៏មុខជាទង្គិចគ្នាយ៉ាងខ្លាំងម្តងទៀត ទូលបង្គំយល់ឃើញជាប្រាកដថា កាលបើមានចិត្តក្តៅក្រហាល់ក្រហាយ ចង់តែស៊ីសាច់ច្របាច់ឈាមគ្នា មាននៅដរាបណាហើយការប្រឹក្សាដើម្បីស្ងប់សឹក រមែងធ្លាក់នៅជាការសូន្យទទេដរាបនោះដូចគ្រាប់ភ្លៀងធ្លាក់លើផែនថ្មដ៏ក្តៅ»។

ក្រឹស្ណៈ «ខ្ញុំនឹកសន្និះសង្កាណាស់ ពាក្យដែលទ្រង់បញ្ចេញមក



នេះ ឃើញជាឃ្លាតឆ្ងាយអំពីសេចក្តីដែលពិត ខ្ញុំដឹងយ៉ាងច្បាស់លាស់ថា យុធិស្ឋិរបានព្យាយាមធ្វើកិច្ចគ្រប់ផ្លូវ ដើម្បីនឹងចៀសវាងឲ្យផុតពីការសង្គ្រាម, ប៉ុន្តែឱរសរបស់ទ្រង់ទេតើ ដែលជាអ្នកប្រឹងប្រែងស្វែងរកសឹកសង្គ្រាម កាប់សម្លាប់គ្នាដោយចិត្តពាលយង់ឃ្នងទៅវិញ ការដែលលើកយកអាថ៌កំបាំងក្នុងចិត្តទៅប្រហារអ្នកដទៃនោះជារាជការវៀច មិនធ្លាប់កើតមានប្រាកដក្នុងចិត្ត ដ៏ទៀងត្រង់របស់យុធិស្ឋិរឡើយ ខ្ញុំមិនចង់នាំយករឿងគំនិតខូច ដែលធ្វើឲ្យអនាថបាណ្ឌពបានទទួលទោសទណ្ឌកម្មមកហើយ ដោយតុណ្ហីភាពនោះទេ, លេងស្កាភ្នាល់ដោយឧបាយកលកោង, រឿងគិតផ្តាច់ផ្តិលជីវិតគ្នា, រឿងរឹបអូសរាជ្យសម្បត្តិយកមកជាប្រយោជន៍របស់ខ្លួន, រឿងប្រមាថមើលងាយគ្នាក្នុងទីប្រជុំជន និងរឿងទុរាចារដែលបានធ្វើដល់ទ្រៅបទីដោយគ្មានអាយសម្បត្តិសោះ, សេចក្តីអាក្រក់លាមកនេះជាការដំណៀលនៅស្ថិតស្ថេរវៀងរហូតទៅ ធ្វើឲ្យកេរ្តិ៍របស់កុរុវង្សស្អុយរលួយរកទីបំផុតគ្មាន ត្រង់កិច្ចនេះត្រូវតែបែរទៅរកកម្លាំងទាហានវិញ ព្រោះគ្មានផ្លូវនឹងត្រឡប់សះជាគ្នាវិញទេ, គ្មានផ្លូវកែខៃ, គ្មានផ្លូវផ្សះផ្សារ ឲ្យកើតមេត្រីភាពវិញទេ, គ្មានអ្វីនឹងយកមកលុបលាងអសត្យរបស់បងប្អូនឯងនេះ ឲ្យជ្រះស្រឡះបានឡើយ, ទ្រព្យសម្បត្តិដែលវិនាសទៅ អាចនឹងឃើញមកវិញបាន, ផែនដីដែលខូចខាតទៅហើយ អាចនឹងវាយដណ្តើមយកមកវិញបាន, ឯកេរ្តិ៍ឈ្មោះដែល

ស្អុយរលួយខូចទៅហើយ ឈ្មោះថាខូចរហូតជានិរន្តរកាល, ពួកបាណ្ឌពក្សត្រិយ៍បានទទួលទោសទណ្ឌកម្មត្រាំត្រែង កើតពីអាការៈបៀតបៀនទាំងនេះដោយខន្តី ដោយសេចក្តីព្យាយាមខ្លាំងក្លា និងមានះ រឿងមកអស់កាលជាយូរអង្វែងហើយ ឥឡូវនេះគេស្រែកសុំដោយសម្លុត មិនមែនជាការសងសឹកយ៉ាងជ្រោកជ្រាកទេ, គេសុំទទួលសិទ្ធិមតិកដ៏ជាភាគរបស់គេ ដោយត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ គេមិនចង់បានរាជ្យសម្បត្តិរបស់ទ្រង់ទេ គឺគេសុំតែដែនដីរបស់គេវិញ ល្មមតែនឹងតាំងខ្លួនជាឥស្សរៈបាន ឲ្យល្មមសមនឹងឋានៈជាក្សត្រិយ៍, ឲ្យល្មមសមដល់ឋានៈជាមនុស្ស ដ្បិតគេនឹងអាស្រ័យភិក្សាហារចិញ្ចឹមជីវិត ដូចយ៉ាងវណ្ណិពួកព្រាហ្មណ៍ទាំងឡាយមិនបានឡើយ, ក្នុងនាមនៃមនុស្សជាតិបាណ្ឌព ខ្ញុំសូមក្រោកឈរឡើងដើម្បីសុំសេចក្តីស្ងប់សឹកម្តងទៀត និងស្រែកសុំយល់ទាស់ក្នុងរឿងច្បាំងកាប់សម្លាប់គ្នា»។

លំដាប់នោះ ក្រឹស្ណៈស្តេចយាងទៅឯដំណាក់ទុរយោធន៍ ដោយបំណងនឹងសុំសម្រុះសម្រួលគ្នាឲ្យគេយល់ស្របផង តាមសេចក្តីយល់ឃើញរបស់ទ្រង់ដែលប៉ុនប៉ងតែខាងផ្លូវស្ងប់សឹក ។ ទ្រង់បានជ្រាបហើយថាធ្រួតរាស្ត្រ គ្មានសំដីអ្វីនឹងគេក្នុងផ្លូវរាជការស្រុកទេសទេ, ទ្រង់ជ្រាបថា ភីស្មៈ ក្សត្រិយ៍ចាស់ សូម្បីមានព្រះហឫទ័យបង្អោនទៅក្នុងផ្លូវសន្តិភាព ក៏មិនអាចឆ្លើយតបតនឹងទុរយោធន៍បានដែរ,



ទ្រង់ជ្រាបថា ទោណ, កណ៌ និងពួកគោរព ដ៏ជាទីប្រឹក្សាឯទៀត ក៏សុទ្ធតែជាខ្ញុំនៅក្រោមបង្គាប់បញ្ជារបស់ទុរយោធន៍ទាំងអស់ ទើបទ្រង់ចិន្តាថា បើទ្រង់និយាយបន្ទន់ចិត្តទុរយោធន៍ មិនឲ្យធ្វើចម្បាំងបាន ទាំងការលំបាករញ៉ីករញ៉ៃកគ្រប់យ៉ាង ក៏ឈ្មោះថាបានសម្រេចស្រេចអស់ដែរ ប៉ុន្តែមិនដូច្នោះ បែរជាពាក្យប្រឹក្សាសើរើរបស់ក្រឹស្ណៈដែលគួរនឹងលួងលោមចិត្តទុរយោធន៍ឲ្យត្រជាក់ ហើយទន់ទោរទៅរកផ្លូវសន្តិភាពនោះ ត្រឡប់ទៅជាពាក្យបង្អៅទុរយោធន៍ឲ្យកើតមានះ របឹងរឹងរូសអួតខ្លាំងពូកែឡើងលើសមុនទៅវិញ ។ ទុរយោធន៍បែរព្រះភក្ត្រមកខាងក្រឹស្ណៈ ហើយត្រាស់ថា «ម្តេចក៏ទ្រង់សម្តែងអាការៈជិនឆ្អន់នឿយណាយនឹងខ្ញុំម្ល៉េះ»។

ក្រឹស្ណៈ ខ្ញុំជាមិត្រនឹងទ្រង់មិនបានទេ ដរាបណាដែលទ្រង់ត្រឡប់ប្រែចិត្តគំនិតឲ្យល្អប្រពៃក្នុងរវាងបាណ្ឌព ជាគណៈញាតិរបស់ទ្រង់វិញទេដរាបនោះ»។

ក្រឹស្ណៈបញ្ចុះបញ្ចូលទុរយោធន៍ ឲ្យត្រឡប់ផ្លាស់ចិត្តមិនបានសម្រេចហើយ ក៏ស្តេចទៅរកអ្នកដទៃទៀត បានជាធ្វើយ៉ាងនេះដោយបំណងនឹងរកគ្នីគ្នាឲ្យបានច្រើននាក់ ជួយទម្រុឧទម្រោមយោបល់របស់ទុរយោធន៍ឲ្យរសាយបាត់ទៅ, បានចូលទៅរកវិទូរថ្លែងរឿងនោះតាមការ គេក៏មានសេចក្តីជឿស្តាប់ ក្នុងរឿងប្រឹក្សាការស្ងប់សង្គ្រាមនោះដែរ ដោយគេឃើញស្រួលគ្រប់ផ្លូវតាមធម៌ គេខូល

ទ្រង់ថា «ទុរយោធន៍ធ្វើមិនស្បិត បិទត្រចៀក ធ្វើមិនឮក្នុងសម្លេងស្រែកសុំ ដ៏ត្រឹមត្រូវតាមផ្លូវយុត្តិធម៌ទេ ព្រោះចិត្តរបស់គេ ចង់តែស៊ីសាច់ប្របាច់ឈាមឲ្យទាល់តែបាន បើទ្រង់កុំយាងមកកាន់ទីនេះ ឲ្យសោះតែម្តងល្អជាជាង ។ ទុរយោធន៍មុខជានឹងមិនជឿស្តាប់ពាក្យមនុស្សណាម្នាក់ឡើយ អ្នកមកនិយាយឲ្យតែខាតពេលទទេ ហាក់ដូចនិយាយចោល កាលបើគេនិយាយសំដីអ្វីឡើង គេត្រូវការតែឲ្យមនុស្សក្នុងសកលលោកយល់ស្របតាមគេទាំងអស់ នឹងទទឹងទាស់មិនបាន»។

ក្រឹស្ណៈ «មនោសញ្ចេតនារបស់យើង គឺនឹងការពារមិនឲ្យកើតសង្គ្រាមតែប៉ុណ្ណោះ ដែលយើងខំកាត់មកកាន់ក្រុងហាស្តិនបុរទាំងម្លេះដើម្បីនឹងជួយពួកកុរុ ឲ្យរួចផុតអំពីសេចក្តីវិនាស ដែលគេខំរកយកមកដាក់ខ្លួនគេ. បើគេជឿស្តាប់យើង គេរាល់គ្នានឹងនៅជាសុខនិរាសភ័យ បើគេប្រមាថមើលងាយពាក្យណែនាំរបស់យើងហើយ គេនឹងបានទទួលសេចក្តីទុក្ខវេទនាជាវង្វាន់តែម្យ៉ាងប៉ុណ្ណោះ» ។

លុះព្រឹកឡើង មានការប្រជុំគណៈរដ្ឋមន្ត្រីជាមហាសន្និបាត ផ្សិតឱកាសនោះ ក្រឹស្ណៈបានចូលទៅនិយាយសម្រួបសម្រួមការស្ងប់សឹកម្តងទៀត ក្នុងទីមហាសន្និបាត នោះទ្រង់ត្រាស់នឹងព្រះបាទធ្ឫតរាស្ត្រ ថា «ខ្ញុំមកនេះ មិនមែនជាមកស្វែងរកសង្គ្រាមទេ ខ្ញុំមកដើម្បីនឹងទម្រុឧទម្រោម កុំឲ្យកើតសឹកសង្គ្រាម ឲ្យត្រឡប់មានចិត្តអាណិត



មេត្តាស្នេហានឹងគ្នាទៅវិញ មហារាជ ! ចូរទ្រង់កុំគាប់ព្រះទ័យក្នុងអកុសលកម្មដ៏ជាគ្រឿងសៅហ្មងចិត្តនោះឡើយ ចូរលើកព្រះហស្តឡើងឲ្យពរជ័យសួស្តីមង្គលដល់ប្រទេស បំបាត់ឧបទ្រពភ័យដ៏មានកម្លាំង ដែលនឹងចូលមកញាំញីយាយីរាជធានី និងព្រះរាជវង្សានុវង្សរបស់ទ្រង់ឲ្យអស់រលីងចេញ ចូរព្រមព្រៀងគ្នាលើកដែនដីក្រុងឥន្ទ្របថ ឲ្យទៅបាណ្ឌពក្សត្រិយ៍ដោយស្រួល ៗ ទៅតាមសម្រែកស្រែកសុំដ៏ត្រឹមត្រូវ តាមគន្លងធម៌ កុំធ្វើឲ្យកើតវឹកវរ ចលាចលរករឿងនឹងគេឡើយ បើទ្រង់ធ្វើបានដូច្នេះហើយ ប្រទេសរបស់ទ្រង់នឹងរុងរឿងកិត្តិយសខ្ពស់មុខប្រាសចាកសព្វភ័យ ល្បីនាមខ្ទរខ្ទារតទៅ សុំឲ្យទ្រង់ត្រិះរិះមើល ប្រសិនបើជាច្បាំងគ្នាទៅហើយបាណ្ឌពក្សត្រិយ៍ ចាញ់ស្លាប់អស់ក្នុងទីយុទ្ធភូមិសោត តើទ្រង់នឹងបានរបស់អ្វីអំពីគេមកមួយទៀត ការស្លាប់ដោយថ្វីដៃរបស់ទ្រង់ដូច្នោះ នឹងធ្វើឲ្យទ្រង់រីករាយសប្បាយព្រះទ័យបានដែរឬ ? គេជាព្រះរាជឱរសរបស់ព្រះអនុជាធិរាជរបស់ទ្រង់ ត្រូវជាព្រះនត្តារបស់ទ្រង់មិនមែនឬ ? ប៉ុន្តែ ខ្ញុំសុំថ្លែងក្នុងទីប្រជុំដ៏សង្ហានេះ សូមឲ្យជ្រាបថា ពួកបាណ្ឌពត្រៀមទុកព្រមស្រេចដើម្បីនឹងធ្វើសង្គ្រាម ហើយថែមទាំងត្រៀមទុកដើម្បីនឹងធ្វើឲ្យសន្តិភាពស្មើគ្នាទៀត ទ្រង់នឹងសព្វព្រះទ័យទទួលយកខាងចម្បាំង ឬយកខាងសន្តិភាព អាចនឹងទទួលយកខាងណាមួយ បានមួយរំពេច ប៉ុន្តែបើប្រសិនជាកើតការចម្បាំងគ្នាឡើង ពួកចិន្តក្រវី និង

ចារិករឿងចម្បាំងនោះទុកក្នុងពង្សាវតារ លោកពណ៌នាតាមលំអានរឿង ដែលពេញពោរទៅដោយការឥតសច្ចៈ, ទ្រង់ជ្រាបឬទេថា ការសង្គ្រាមបែបនេះព្រះជាម្ចាស់លើស្ថានសួគ៌ លោកហាមប្រាមទុករួចហើយ អើ ! កាលបើយើងឈានចុះកាន់សង្គ្រាមហើយ តើអ្នកណាអាចនឹងព្យាករបានថានឹងចប់ចុះត្រឹមមរណកាលនៃបាណ្ឌពក្សត្រិយ៍ ឬត្រឹមផុតរលត់អស់ពូជពង្សកុរុ ។

កាលព្រះបាទធ្ឫតរាស្ត្រ បានទ្រង់ព្រះសណ្ដាប់ពាក្យសម្រួបសម្រួមនៃក្រឹស្ណៈ សព្វ ៗ ទៅហើយ ទ្រង់មានទុក្ខព្រួយព្រះហឫទ័យណាស់ ដ្បិតតាមធម្មតារបស់ទ្រង់ជាអ្នកមានធាតុទន់ខ្សោយ ប៉ុន្តែទ្រង់ត្រាស់ដោះសាកែព្រះអង្គថា «ខ្ញុំមិនដឹងបើនឹងគិតឆ្លាស់ឆ្លៀតកែខៃនិស្ស័យកំណាចរបស់ឱរសដូចម្ដេចបានទេ អស់ផ្លូវនឹងជួយជ្រោមជ្រែងហាមឃាត់ទៀតហើយ»។

លំដាប់នោះ ភីស្មៈក្រោកឈរឡើងថ្លែងសន្ទរកថាដាស់តឿនស្មារតីទុរយោធន៍ តាមពាក្យណែនាំដ៏ប្រសើររបស់ក្រឹស្ណៈ ប៉ុន្តែទុរយោធន៍ស្ដាប់ចប់ហើយក៏នៅស្ងៀមព្រងើយ ធ្វើហាក់ដូចជាមិនឮ តែក្នុងព្រះទ័យក្ដៅក្លួលពុលខ្នួលស្នើរស្រក់ព្រះលោហិត ។

ទោណ, វិទូរ, នារទ និងអ្នកឯទៀតក្រៅពីនេះ មានសេចក្ដីយល់ឃើញស្របតាមគំនិតភីស្មៈ ព្រមសុខចិត្តដំណើរការតាមភីស្មៈដែរ ទើបចូលមកអង្វរទុរយោធន៍ សុំកុំឲ្យប្រគាន់អំណាចរាជសម្បត្តិ



ខ្លាំងពេក, ចេះតែផ្លាស់មុខគ្នាចូលមកអង្វរត ៗ គ្នាជាច្រើននាក់ ។ ទុរយោធន៍នឹងទ្រាំសម្ងំអង្គុយឲ្យគេលួងលោមតទៅទៀតពុំបាន ក៏ក្រោកឈររួចដំឡើងព្រះនេត្រក្រឡោត ចងចិញ្ចើមក្រញូវត្រាស់ថា «ក្រឹស្ណៈស្អប់មុខយើងណាស់ ហើយទៅស្រឡាញ់ខាងពួកបាណ្ឌពវិញ, ឯភីស្មៈធ្វើព្រះនេត្រតឹងមករកយើង, វិទូរ និងទោណ ដាក់មុខថ្មឹងសម្លឹងសម្លក់យើងដោយសំអប់, ឯព្រះរាជបិតាយើងសោតទៀតក៏ទ្រង់ព្រះកន្សែងថ្លែងទុកពីរឿងបាបកម្មរបស់យើង និងភ្លូញភ្លែរដើម្បីឲ្យស្ងប់សឹក, បានជាដូច្នោះ តើដោយឃើញយើងធ្វើអំពីល្មើសអ្វីខ្លះរួចទៅហើយ, មួយទៀត បើចេះតែប្រព្រឹត្តបែបនេះទៅ តើឲ្យយើងជាក្សត្រិយ៍អ្នកទ្រង់នូវឥស្សរភាព នឹងលូកដៃទៅធ្វើអ្វី ?

លោកអ្នកធំទាំងឡាយអើយ ! សូមឲ្យលោកជួយគិតមើលមួយរំពេចសិន, តើយុធិស្ឋិរចូលចិត្តលេងល្បែងភ្នាល់ ហើយបានចូលលេងស្កាភ្នាល់ ទាល់តែខ្ទុកទ្រព្យសម្បត្តិ និងឥស្សរភាពដោយគំនិតរបស់ខ្លួន ហេតុម្ដេចក៏មកពាលោករឿងនឹងយើង ថាយើងជាមនុស្សខូចកាចទៅវិញ ? កាលគេលេងស្កាភ្នាល់ក្នុងលើកទីពីរចាញ់យើងហើយ ហើយព្រមសុខចិត្តទទួលទោសនិរទេសដោយខ្លួនឯង ហេតុម្ដេចក៏ហ៊ានមកចោទប្រកាន់យើង ថាយើងជាចោរទៅវិញ ? ជោគជតារាសីរបស់បាណ្ឌពគ្រានេះ ធ្លាក់ត្រណាត់ត្រណែង ទៅតាមយថាកម្មរបស់គេ, ឯបក្សពួករបស់គេសោតទៀត ក៏មិនមានប៉ុន្មាន

នាក់ដែរ ទាំងកម្លាំងរេហ៍ពលក៏មិនសូវជាមាំទាំ មិនធួននឹងការប្រឡងប្រជែងយកជ័យជម្នះទេ, ខ្លួនយើងជាមនុស្សមិនធ្លាប់កោតក្រែងព្រះលើស្ថានសួគ៌ ហើយត្រឡប់ជាមកញញើតសំដីគំរាមកំហែងរបស់មនុស្សរបិុចរប៉ីកំទេចកំទីបែបនេះកើតដែរឬអី ? ជាតិក្សត្រិយ៍អាចនឹងស្លាប់បង់ជីវិតក្នុងទីស្នាមប្រឡងសឹកក៏បាន ប៉ុន្តែមិនព្រមឱនលំទោនចុះចាញ់អ្នកណាទេ នេះជាពាក្យរបស់លោកអ្នកប្រាជ្ញពោលទុកមក ឥឡូវនេះអញ្ជើញអស់លោកជាព្រះញាតិទាំងឡាយស្តាប់ពាក្យខ្ញុំថ្លែងខ្លះវិញផង ៖ ព្រះរាជបិតារបស់យើងបានលើកអាណាចក្រឥន្ទ្របថឲ្យទៅបាណ្ឌព ក្នុងវេលាដែលទ្រង់កំពុងតែវង្វេងស្រឡាញ់កូនក្មួយ ឬបើមិនដូច្នោះទេ ក៏ទ្រង់ធ្លោយមិនបានជាគិតឲ្យសព្វគ្រប់អំពីផ្លូវរាជការសម្រាប់ស្រុកទេស បើជីវិតរបស់យើងមាននៅដរាបណា ពួកបាណ្ឌពនឹងមិនបានជាម្ចាស់ខែត្រខណ្ឌសីមាឥន្ទ្របថទៀតជាដាច់ខាត ដរាបនោះ រាជអាណាចក្រកុរុនឹងមិនត្រូវបែងចែកជាពីរភាគឡើយ បានមករួមនៅក្នុងដែនទីជាមួយគ្នា ហើយត្រូវតែនៅរួមគ្នាដដែលជានិរន្តរកាលទៅ ។ ពាក្យរបស់ខ្ញុំដែលថ្លែងមកប៉ុណ្ណេះ ជាពាក្យច្បាស់លាស់ណាស់ ជាពាក្យមាំទាំណាស់ គ្មានព្រលាំត្រង់ណាទេ មិនត្រឡប់ប្រែប្រួលទៅជាពាក្យពីរបានឡើយ» ។

ក្រឹស្ណៈក៏បានជ្រាបរួចហើយថា គ្មានប្រយោជន៍អ្វីក្នុងរឿងនេះទេ បើទុកជាលើកយកយុត្តិធម៌មកលាតលាត្រដាងយ៉ាងណាទុរ-



យោធន៍ ក៏នៅតែមិនយល់ស្របតាមតែ ព្រោះថាមនុស្សមាននិស្ស័យរបឹងរឹងរូស ត្រាំស្អិតក្នុងសន្តានមកយូរហើយ ប៉ុន្តែដរាបណានៅមានឱកាសនិយាយ ក៏អត់ទ្រាំនិយាយមិនបានដរាបនោះ គ្រានេះក៏ទៀតដែរ ក្រឹស្ណៈត្រាស់ថា «ទុរយោធន៍អើយ ! ម្តេចទ្រង់និយាយយ៉ាងនេះរួច ម្តេចទ្រង់បំភ្លេចចោលត្រង់ពាក្យថា ទ្រង់នឹងមិនល្មើសច្រើសឃ្លងរំលងរំលោភលើបងប្អូនឯង» ។

ទុហាសាសនៈ បែរទៅខ្សឹបទូលទុរយោធន៍ពីរបីមាត់រំឭកឲ្យដឹងខ្លួនថា «ក្រែងកើតហេតុជាធំដុំបាន ព្រោះការដែលមករឹងទទឹងអ្នកធំអ្នកប្រាជ្ញជាច្រើននាក់ក្នុងទីមហាសន្និបាតនេះ»។

ទុរយោធន៍ បានស្តាប់ពាក្យអនុជទូលដាស់តឿនមិនទាន់បានតបឆ្លើយឆ្លងសំដី ក្រឹស្ណៈ និងទុហាសាសនៈសោះ ក៏ក្រោកក្រេសយាងចេញអំពីទីប្រជុំរដ្ឋមន្ត្រី ព្រះភក្ត្រឡើងច្រាលដោយទោសៈ ។

ព្រះរាជាធ្ឫតរាស្ត្រ បានពន្យល់ហេតុផលផ្សេង ៗ ជាច្រើនឲ្យឱរសមុខរឹងស្តាប់ម្តងទៀត ។ ព្រះនាងគន្ធារីជាជននីនៃទុរយោធន៍ក៏យល់ឃើញតាមព្រះវាចាមហារាជនោះដែរ តែទោះបីដូច្នោះក្តី ទុរយោធន៍ក៏ទៅតែមិនព្រមផ្លាស់គំនិតអាក្រក់នោះចោលចេញ នៅតែចចេសដោយឥតក្រែងអ្នកណាសោះ ។

ក្រឹស្ណៈឃើញថា សេចក្តីព្យាយាមសម្រួបសម្រួមរបស់ព្រះអង្គក្នុងទីបំផុតនេះរលំរលាយបាត់បង់ហើយមិនបានសម្រេចប្រយោជន៍

ដូចបំណងនោះ ក៏ស្ដេចយាងចេញចាកក្រុងហាស្តិនបុរ លុះទៅដល់ក្រុងវិរាជវិញហើយ ក៏សាស័ព្ទហេតុការណ៍ទាំងពួង ដែលប្រព្រឹត្តទៅក្នុងរាជសំណាក់កុរុ ឲ្យយុធិស្ធិរស្ដាប់តាមដំណើរគ្រប់ប្រការ ។